# ទំនប់ ទន្លេ និងសិទ្ធិ

## គោលការណ៍ណែនាំសកម្មភាពសំរាប់សហគមន៍ ដែលរងផលប៉ះពាល់ពីការសាងសង់ទំនប់




IRN
International Rivers Network
Linking Human Rights and Environmental Protection

# ទំនប់ទឹក ទន្លេ និង សិទ្ធិ

## គោលការណ៍ណែនាំសកម្មភាពសំរាប់សហគមន៍

## ដែលរងការប៉ះពាល់ពីទំនប់ទឹក

## **អំណរគុណ**

គោលការណ៍ណែនាំសកម្មភាពនេះ គឺបានផលិតឡើងក្រោមការឧបត្ថម្ភយ៉ាងសប្បុរសរបស់ **អុកហ្វាម អូស្ត្រាលី** (Oxfam Australia) និង **មូលនិធិហ្វដ** (Ford Foundation) ។ អត្ថបទនៅក្នុងឯកសារនេះ គឺបានសរសេរឡើងដោយ **អាវីវ៉ា អ៊ីមហូហ្វ** (Aviva Imhof) **អាន់ ខាតព្រីន ស្នេឌើរ** (Ann Kathrin Schneider) និង **ស៊ូសាន វ៉ង់** (Susanne Wong) ។ **ស្តានណុន ឡរេនស៍** (Shannon Lawrence) បានកែសម្រួលពង្រាងចុងក្រោយ និង **ជេមី គ្រីនប្លែត** (Jamie Greenblatt) បានជួយធ្វើការអានពិនិត្យសារឡើងវិញ។ **ត្រេស៊ី ពើរគីន** (Tracy Perkins) បានផ្តល់ការជួយជ្រោមជ្រែងដែលមិនអាចកាត់ថ្លៃបាន និងជំនាញក្នុងការរៀបគោលគំនិតបង្កប់ក្នុងរូបភាពសំរាប់ពន្យល់ទ្រទ្រង់ទ្រាយឯកសារ និងទិសដៅទូទៅរបស់គំរោង។ សូមថ្លែងអំណរគុណផងដែរជូនចំពោះ **ហារីស អ៊ិច វ៉ាន** (Haris Ichwan) ដែលបានគូររូបភាពពន្យល់យ៉ាងស្រស់ស្អាត។ សូមអរគុណផងដែរជូន **មូលនិធិហិសពើរៀន** (Hesperian Foundation) ចំពោះការរួមគ្នាជាមួយយើងដើម្បីប្រើប្រាស់រូបភាពពន្យល់ដែលបានមកពីបណ្ណុំរូបភាពជាច្រើនដែលពួកគេបានប្រមូលទុក។

សូមថ្លែងអំណរគុណជាពិសេសជូនក្រុមផ្តល់ប្រឹក្សាយោបល់របស់យើងចំពោះការផ្តល់យោបល់ និងការណែនាំយ៉ាងច្រើន និងការធ្វើតេស្តសាកល្បងមើលគោលការណ៍ណែនាំនេះជាមួយសហគមន៍ជាច្រើនដែលរងការប៉ះពាល់ពីទំនប់ទឹក។ គោលការណ៍ណែនាំនេះ ត្រូវបានជំរុញអោយចេញជារូបរាងឡើងដោយសេចក្តីក្លាហាន និងគតិបណ្ឌិតរបស់ប្រជាជនដែលរងការប៉ះពាល់ពីទំនប់ទឹក និងសម្ព័ន្ធជាច្រើនរបស់ពួកគេនៅជុំវិញពិភពលោក។

សមាជិកក្រុមផ្តល់ប្រឹក្សាយោបល់រួមទាំង **ជិរិន ចេតធា** (Girin Chetia - ឥណ្ឌា) និង **ភៀនផន ឌីទីស** (Pianporn Deetes – ថៃឡង់ដ៍) **អ៊ីរ៉ា ប៉ាម៉ាត** (Ira Pamat – ហ្វ៊ីលីពីន) **ហ្វ្រែងឃ្លីន រ៉ូថម៉ែន** (Franklin Rothman – ប្រេស៊ីល) **ខេវីន វូដ** (Kevin Wood – ថៃឡង់ដ៍/US) និង **អើរខេន អាយបូហ្គា** (Ercan Ayboga – តួរគី/គួរឌីស្ថាន) ។

រូបភាពពន្យលដើមរបស់ **ហារិស អ៊ិចវ៉ាន** (Haris Ichwan) ។ មានបង្ហាញនៅលើទំព័រលេខ ៧ ១០ (នៅខាងលើ) ទំព័រលេខ ១១ ១២ (នៅខាងក្រោម) ទំព័រលេខ ១៣ ១៤ ១៨ ១៩ (នៅខាងក្រោម) ទំព័រលេខ ២០ ២៣ ២៨ (នៅខាងក្រោម) ទំព័រលេខ ៣០ (នៅខាងក្រោម) ទំព័រលេខ

៣២ ៣៣ (នៅខាងក្រោម) និង ទំព័រលេខ ៣៦ ដែលបានសំដែងអោយឃើញនូវសុជីវធម៌របស់**ម៉ូលនិធិហិសពើរៀន** (Hesperian Foundation) ។

រៀបបែបផែនដោយ **ឌីសាញ អ៊ែកស្សិន ខឡិកធីវ** (Design Action Collective)

បោះពុម្ពដោយ **អ៊ិងវើក ប្រេសស៍** (Inkworks Press)

បោះពុម្ពផ្សាយដោយ **អ៊ិនធើរនេស្សិនណាល់ រីវើរ នេធវើក** (International Rivers Network, 2006 – បណ្តាញទន្លេអន្តរជាតិ ឆ្នាំ ២០០៦) ។

1847 Berkeley Way, Berkeley CA 94703, USA
ទូរស័ព្ទ : +1 510 848 1155, ទូរសារ : +1 510 848 1008, info@irn.org, www.irn,org

ISBN-10: 0-97188-584-2
ISBN-13: 978-0-97188-584-4

# ពាក្យពិបាក

**សំណង** : លុយ ឬ វត្ថុផ្សេងទៀតដែលផ្តល់អោយប្រជាជនដើម្បីប៉ះប៉ូវការខូចខាត ។

**បញ្ឈប់ដំណើរការ** : គឺកំទេចទំនប់ទឹកចោល ឬ ឈប់ប្រើប្រាស់វា ។ ប្រការនេះអាចពាក់ព័ន្ធដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធរបស់ទំនប់ទឹក បើកចំហទ្វារទឹករបស់វាជាអចិន្ត្រៃ ឬយកទំនប់ចេញ (កំទេច) ។

**ផ្លាស់ទីជម្រក** : អោយប្រជាជនរើចេញពីផ្ទះ និង ដីរបស់ពួកគេ ។

**តំបន់ក្រោមទំនប់** : តំបន់ដែលតាំងនៅក្រោមដងទន្លេ ឬ ស្ទឹងដោយគិតពីទំនប់ទឹកមក ។

**អង្កេតមូលដ្ឋាន** : ព័ត៌មានដែលប្រមូលបានតាមរយៈការនិយាយជាមួយប្រជាជននិងពិនិត្យវត្ថុផ្សេងៗដោយផ្ទាល់ ។

**ការសម្រាល** : វិធានការកាត់បន្ថយឥទ្ធិពលរបស់ទំនប់ ។ គេអាចដាក់បញ្ចូលនូវការបង្កើតជម្រកសត្វព្រៃ បញ្ចេញទឹកចូលទៅក្នុងតំបន់ក្រោមទំនប់ហើយផ្តល់ប្រាក់ចំណូល និងមុខរបរថ្មីដល់ប្រជាជនដែលរងការប៉ះពាល់ ។

**អង្គការមិនមែនរដ្ឋាភិបាល (NGO)** : គឺជាអង្គការដែលឯករាជ្យពីរដ្ឋាភិបាល ។

**សកម្មភាពផ្ទាល់មិនហិង្សា** : ព្រឹត្តិការដោយសន្តិវិធីដែលគេរៀបចំឡើងដើម្បីដាក់សម្ពាធលើអ្នកធ្វើសេចក្តីសំរេចនិងលើកស្ទួយការយល់ដឹងរបស់សាធារណជនអំពីការខំប្រឹងប្រែង ។

**ធនាគារអភិវឌ្ឍន៍សាធារណៈ** : ជាធនាគារអន្តរជាតិ ដូចជាធនាគារពិភពលោក ឬ ធនាគារអភិវឌ្ឍន៍រវាងជនជាតិអាមេរិក (Inter-American Development Bank) ដែលផ្តល់ប្រាក់កម្ចីដល់រដ្ឋាភិបាល ឬ ក្រុមហ៊ុនផ្សេងៗសំរាប់ការអភិវឌ្ឍន៍ ។ ធនាគារអភិវឌ្ឍន៍សាធារណៈគឺគ្រប់គ្រងដោយរដ្ឋាភិបាល ។

**រៀបប្រតិបត្តិការឡើងវិញ** : ការផ្លាស់ប្តូរប្រតិបត្តិការរបស់ទំនប់ដើម្បីអោយទន្លេ ឬ ស្ទឹងហូរតាមធម្មជាតិកាន់តែខ្លាំងឡើង ។

**សំណងការខូចខាត** : លុយ ឬ វត្ថុផ្សេងទៀតដែលផ្តល់អោយដើម្បីជំនួសការបាត់បង់ ឬ សងចំពោះកាខូចខាតដែលបណ្តាលមកពីទំនប់ទឹកដែលកំពុងមានរូបរាងនៅឡើយ ។

**អាងស្តុកទឹក** : បឹងដែលគេបង្កើតឡើងក្នុងពេលដែលទំនប់ត្រូវបានគេកសាង ។

**ការតាំងទីលំនៅថ្មី** : ការចល័តប្រជាជនចូលទៅក្នុងភូមិថ្មី ឬភូមិដែលមានស្រាប់ដើម្បីទុកកន្លែងអោយគេសង់ទំនប់ ។

**ស្គីសតូសូមីយ៉ាស៊ីស (Schistosomiasis) :** ជំងឺដែលបណ្តាលមកពីការប៉ះពាល់ជាមួយខ្សងប្រភេទជាក់លាក់ដែលរស់នៅក្នុងប្រឡាយទឹកសាប ទន្លេ ឬ បឹង ។

**ល្បាប់ :** ខ្សាច់ កំទេចដី និងថ្មដែលដោយមកតាមទឹកស្ទឹង ។

**តំបន់លើទំនប់ :** តំបន់ដែលតាំងនៅលើទំនប់ ដោយគិតទាំងអាងស្តុកទឹក និង កន្លែងនៅខាងលើឆ្ងាយពីស្ទឹង ឬ ទន្លេ ។

**គណៈកម្មាធិការពិភពលោកទទួលបន្ទុកទំនប់ទឹក :** គណៈកម្មាធិការអន្តរជាតិឯករាជ្យដែលគេបង្កើតឡើងដើម្បីសិក្សាការបំពេញមុខងាររបស់ទំនប់ទឹក ពិនិត្យមើលដំណោះស្រាយផ្សេង ហើយធ្វើអនុសាសន៍សំរាប់ការកសាងទំនប់នៅអនាគត ។ របាយការណ៍ចុងក្រោយដែលបានចេញនៅឆ្នាំ ២000 ។ ព័ត៌មានដែលអាចរកបាន តាមគេហទំព័រ www.dams.org ។

# មាតិការឿង


**សេចក្តីផ្តើម**........................................................................................................២

**ជំពូក ១ : ព័ត៌មានចាំបាច់អំពីទំនប់** ..................................................................................៣

ទំនប់គឺជាអ្វី ?..............................................................................................................៣

តើទំនប់ធ្វើអ្វីខ្លះ?............................................................................................................៣

អ្នកខ្លះទទួលផលចំណេញ? អ្នកណាខ្លះទទួលរងការខូចខាត?...............................................៤

តើទំនប់ទឹកបំពេញមុខងារដូចម្តេច?.....................................................................................៥

អ្នកណាជាអ្នកចំណាយលុយធ្វើទំនប់ទឹក?........................................................................ .៦

**ជំពូក ២ : ឥទ្ធិពលអាក្រក់របស់ទំនប់**..................................................................................៧

គំនូរ : ឥទ្ធិពលអាក្រក់របស់ទំនប់...... ...............................................................................៨

សភាពពិតនៃការផ្លាស់ទីលំនៅ...........................................................................................១០

ប្រជាជនរាប់លាននាក់រងការប៉ះពាល់នៅតំបន់ក្រោមទំនប់.................................................១២

**ជំពូក ៣ : ចលនាអន្តរជាតិប្រឆាំងទំនប់ដែលមានលក្ខណៈបំផ្លាញ**...........................................១៤

ជោគជ័យរបស់អ្នកប្រឆាំងនឹងទំនប់..................................................................................១៥

ជោគជ័យ...ប៉ុន្តែទំនប់នៅតែគំរាមកំហែងសហគមន៍.........................................................១៦

**ជំពូក ៤ : វិធីសាស្ត្រក្នុងការប្រឆាំនឹងទំនប់**...............................................................................១៧

រៀបចំផែនការយុទ្ធនាការណ៏របស់អ្នក.................................................................................១៨

យុទ្ធសាស្ត្រសំខាន់ៗដើម្បីប្រឆាំងនឹងទំនប់ទឹក.....................................................................២០

តើអ្នកអាចធ្វើអ្វីបានខ្លះនៅដំណាក់កាលនីមួយៗនៃការកសាងទំនប់.......................................២៤

**ជំពូក ៥ : ជំរើសផ្សេងក្រៅពីទំនប់**.........................................................................................២៩

ជំរើសផ្សេងទៀតសំរាប់ផលិតថាមពល...............................................................................២៩

ជំរើសផ្សេងទៀតសំរាប់រក្សាទឹក.........................................................................................៣២

វិធីផ្សេងទៀតសំរាប់គ្រប់គ្រងទឹកជំនន់...............................................................................៣៤

**សន្និដ្ឋាន**..........................................................................................................................៣៦

**ទំនាក់ទំនងប្រចាំតំបន់**.........................................................................................................៣៧

# សេចក្តីផ្តើម

នៅជុំវិញពិភពលោក ប្រជាជនកំពុងងើបឡើងប្រឆាំងនឹងទំនប់វារីអគ្គីសនីធំៗ។ ពួកគេកំពុងប្រយុទ្ធដើម្បីការ ពារទន្លេ ស្ទឹងនិងជីវភាពរបស់ពួកគេអោយរួចផុតពីទំនប់ថ្មីៗ។ ពួកគេកំពុងទាមទារអោយមាន **សំណង** ចំពោះបញ្ហាដែលបណ្តាលមកពីទំនប់ចាស់ៗជាច្រើន។ ពួកគេស្នើអោយមានមធ្យោបាយផ្សេងដែលមានលក្ខណៈល្អជាង សំរាប់ថាមពល ការផ្គត់ផ្គង់ទឹក និង ការគ្រប់គ្រងទឹកជំនន់ ។ ពួកគេទាំងអស់គ្នាកំពុងប្រយុទ្ធដើម្បីអោយមានសំលេងនៅក្នុងការសំរេចចិត្តផ្សេងដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

អស់ពេលជាង ២០ ឆ្នាំ មកហើយដែលចលនាអន្តរជាតិប្រឆាំងនឹងទំនប់មានកំលាំងខ្លាំងឡើងហើយមានជោគជ័យជាច្រើនទៀតផង។ ទំនប់ទឹកមួយចំនួនត្រូវបានបញ្ឈប់។ សហគមន៍បានទទួលសំណងច្រើនជាងមុន។ ទំនប់ខ្លះត្រូវបានរុះរើចេញ។

ប៉ុន្តែមានទំនប់ថ្មីៗជាច្រើនដែលបន្តគំរាមកំហែងសហគមន៍ជាច្រើនទូទាំងពិភពលោក។

(បណ្តាញទន្លេអន្តរជាតិ) បានបង្កើតគោលការណ៍ណែនាំសកម្មភាពនេះឡើងដើម្បីផ្តល់អំណាចដល់សហគមន៍ដែលរងការគំរាមកំហែងពីទំនប់ថ្មីៗ និង ដើម្បីចែករំលែកគំនិតដែលបានមកពីចលនាអន្តរជាតិប្រឆាំងនឹងទំនប់។ **បណ្តាញទន្លេអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត (NGOs)** នៅជុំវិញពិភពលោកបានត្រៀមខ្លួនរួចជាស្រេចហើយដើម្បីជួយអ្នកនៅក្នុងការតស៊ូរបស់អ្នក។ អង្គការមិនមែនរដ្ឋា ភិបាលដែលអាចជួយអ្នកបាននោះ គឺមានរាយជាបញ្ជីនៅចុងបញ្ចប់នៃគោលការណ៍ណែនាំនេះ។

យើងសង្ឃឹមថា គោលការណ៍ណែនាំនេះផ្តល់ព័ត៌មាននិងឧបករណ៍សំរាប់ជួយអ្នកសំរេចចិត្តពីរបៀបឆ្លើយតបទៅនឹងទំនប់ដែលគេបានស្នើឡើង របៀបការពារសិទ្ធិរបស់អ្នក និង របៀបទាមទារអោយមានសំលេងមួយនៅក្នុងការសំរេចចិត្តអំពីទំនប់។

- ► នៅខាងដើមនៃគោលការណ៍ណែនាំ គឺជាបញ្ជីពាក្យពិបាកនិងនិយមន័យរបស់ពាក្យទាំងនោះ។ ពាក្យទាំងនេះមានលក្ខណៈ **ខ្មៅក្រាស់** នៅក្នុងគោលការណ៍ណែនាំ។
- ► ជំពូទី ១ មានព័ត៌មានទូទៅអំពីទំនប់ រួមទាំងរបៀបដែលទំនប់ដំណើរការ អ្នកណាទទួលផលចំណេញពីទំនប់ និង អ្នកណាចំណាយលុយកសាងទំនប់។
- ► ជំពូកទី ២ និយាយអំពីឥទ្ធិពលរបស់ទំនប់ទៅលើសហគមន៍ជាច្រើននិងធនធានធម្មជាតិ។

- ជំពូកទី ៣ អធិប្បាយអំពីចលនាក៏រិតអន្តរជាតិរបស់ប្រជាជនប្រឆាំងនឹងទំនប់ដែលមានលក្ខណៈបំផ្លាញ និង ជោគជ័យរបស់ចលនានោះ។
- ជំពូកទី ៥ ផ្តល់ព័ត៌មានអំពីជំរើសដែលមានលក្ខណៈល្អប្រសើរជាងទំនប់ ក្នុងការផ្តល់ទឹកថាមពលដល់ប្រជាជន និង ការគ្រប់គ្រងទឹកជំនន់។
- នៅចុងបញ្ចប់នៃគោលការណ៏ណែនាំនេះ គឺជាបញ្ជីមួយនិយាយអំពីពត៌មានសំរាប់ទំនាក់ទំនងដែលអាចនឹងជួយដល់អ្នក។

យើងសូមជូនពរដល់អ្នក សូមអោយទទួលបានជោគជ័យនៅក្នុងការតស៊ូរបស់អ្នក ប្រឆាំងនឹងទំនប់លក្ខណៈបំផ្លាញ។ យើងគឺជាចលនាមួយនៅក្នុងការតស៊ូរបស់យើងដើម្បីយុត្តិធម៌និងសេចក្តីថ្លៃថ្នូរ។ ទឹកគឺជាជីវិតរស់រាន គឺមិនមែនដើម្បីសេចក្តីស្លាប់នោះទេ។

*បណ្តាញទន្លេអន្តរជាតិ*

# ជំពូក ១

# ព័ត៌មានចាំបាច់អំពីទំនប់វារីអគ្គិសនី

## ■ តើទំនប់វារីអគ្គិសនីគឺជាអ្វី?

ទំនប់គឺជាជញ្ជាំងមួយដែលគេសង់កាត់ទន្លេ ឬ ស្ទឹង។ ទំនប់អាចធ្វើមកពីដី ថ្ម ឬ បេតុង។ វាវាំងស្ទះចរន្តទឹក ហូរ ដោយបង្កើតអោយមានបឹងសិប្បនិម្មិតដែលគេហៅ **អាងស្តុកទឹក** ។ គេអាចប្រើទឹកដែលស្តុកនៅក្នុងអាងដើម្បីបង្កើតអគ្គិសនី ផ្តល់ទឹកសំរាប់ការស្រោចស្រព និង ទឹកសំរាប់ផឹក ដើម្បីជួយដល់ការធ្វើចរាចររបស់ទូក កាណូត ដើម្បីគ្រប់គ្រងទឹកជំនន់ និង សំរាប់ការកំសាន្ត។ ទំនប់ខ្លះត្រូវគេកសាងឡើងអោយមានមុខងារច្រើន ក្នុងចំណោមមុខងារដែលបានរៀបរាប់មកនេះ។

នៅជុំវិញពិភពលោកគេបានកសាងទំនប់ធំៗច្រើនជាង ៤៧.០០០ កន្លែង (ដែលមានកំពស់ខ្ពស់ជាង ១៥ ម៉ែត្រ) ។ ប្រទេសចិន សហរដ្ឋអាមេរិក និង ឥណ្ឌា មានទំនប់ដែលធំជាងគេ។ ទំនប់ដែលធំជាងគេបំផុតក្នុងពិភពលោក គឺមានកំពស់ខ្ពស់ជាង ២៥០ ម៉ែត្រ (ឬ ខ្ពស់ជាងអាគារកំពស់ ៦០ ជាន់ទៅទៀត) ហើយមានទទឹងជាច្រើនគីឡូម៉ែត្រ។ ពួកវាចំណាយលុយអស់រាប់ពាន់លានដុល្លារ និង ចំណាយពេលវាលាជាង ១០ ឆ្នាំក្នុងការសាងសង់។

## ■ តើទំនប់វារីអគ្គិសនីមានមុខងារធ្វើអ្វីខ្លះ?

❖ **ទំនប់សំរាប់ការផ្គត់ផ្គង់ទឹក និងការស្រោចស្រព** ស្តុកទឹកនៅក្នុងអាង។ ទឹកនេះត្រូវបញ្ជូនទៅទីក្រុងជាច្រើន ឬកសិដ្ឋានដោយប្រើបំពង់ធំៗ និង ប្រឡាយ។

❖ **ទំនប់សំរាប់វារីអគ្គីសនី** ប្រើទឹកដើម្បីបង្វិលផ្លិតម៉ាស៊ីនដែលគេហៅថាតួរប៊ីនដើម្បីបង្កើតអគ្គិសនី។ អគ្គិសនីត្រូវបញ្ជូនទៅទីក្រុង ឬរោងចក្រដោយប្រើខ្សែបញ្ជូនចរន្ត។

❖ **ទំនប់សំរាប់គ្រប់គ្រងទឹកជំនន់**សំរាប់ស្តុកទឹកក្នុងពេលមានភ្លៀងធ្លាក់ខ្លាំង ដើម្បីកាត់បន្ថយទឹកជំនន់នៅក្នុង តំបន់ក្រោមទំនប់ ។



*ទំនប់មានច្រើនសណ្ឋាននិងទំហំ ប៉ុន្តែភាគច្រើនមានមានលក្ខណៈពិសេសដូចបង្ហាញក្នុងរូប។*

❖ **ទំនប់សំរាប់ចរាចរ ទូក កាណូត កប៉ាល** ស្តុកទឹក និង បញ្ចេញទឹកនៅពេលដែលទឹក នៅក្នុងទន្លេ ឬ ស្ទឹងមានកំរិតទាបពេក ដើម្បីអោយទូក កាណូត កប៉ាល់អាចបើកបរចុះឡើងបានតាមទន្លេ ឬ ស្ទឹងពេញមួយឆ្នាំៗ។ ជាធម្មតាគេកសាងវាដោយប្រើថ្ម ឬ ឧបករណ៍ដែលលើក ទូក កាណូត ឬ កប៉ាល់ឡើង និង ដាក់ពួកវាចុះ ដើម្បីអាចធ្វើដំណើរឆ្លងកាត់ទំនប់បាន។

## ■ តើអ្នកណាទទួលផលចំណេញ? អ្នកណាទទួលខេការខូចខាត?

រោងចក្រឧស្សាហកម្ម និងពលរដ្ឋទីក្រុងជាច្រើនទទួលផលចំណេញពីថាមពលដែលបង្កើតឡើង និងទឹកដែលស្តុក ដោយទំនប់។ ក្រុមហ៊ុនកសិកម្មខ្នាតធំជាច្រើនទទួលបានគុណប្រយោជន៍ពីទឹកដែលមានតម្លៃថោកសំរាប់ ការស្រោចស្រពដំណាំ។ ជាញឹកញាប់ ទំនប់បានយកផលចំណេញជាច្រើនពិសេសពីតំបន់ជនបទ ហើយផ្តល់ផល ចំណេញទាំងនេះអោយទៅផ្នែកឧស្សាហកម្ម និងប្រជាជនដែលរស់នៅក្នុងទីក្រុង។ ពេលខ្លះឧស្សាហកម្មនិងប្រជាជន ទាំងនេះគឺស្ថិតនៅក្នុងប្រទេសជិតខាង។

ក្រុមហ៊ុនសាងសង់និងវិស្វកម្មក៏ទទួលបានផលចំណេញដូចគ្នាដែរ។ ពួកគេទទួលបានលុយរាប់ពាន់លានដុល្លារពីការរៀបប្លង់និងកសាងទំនប់។ រដ្ឋាភិបាលអាចទទួលបានផលចំណេញពីពន្ធដែលគេប្រមូលបាន ក្នុងអំឡុងពេលកសាងទំនប់ និងក្នុងពេលដែលទំនប់ដំណើរការមុខងាររបស់វា។ ដោយសារ លុយដែលចំណាយលើទំនប់មានចំនួនច្រើននោះ រដ្ឋាភិបាលពុករលួយនិងមន្ត្រីរបស់ក្រុមហ៊ុន ពេលខ្លះយកលុយនោះដាក់ក្នុងហោប៉ៅដើម្បីផលប្រយោជន៍របស់ខ្លួនគេផ្ទាល់។

អ្នកដែលរងការឈឺចាប់ពីទំនប់ធំៗ គឺជាកសិករជនបទ និងអ្នកស្រុកដើម ឬ ប្រជាជនកុលសម្ព័ន្ធ។ ប្រជាជនរាប់លាននាក់ត្រូវបានបង្ខំអោយចាកចេញពីលំនៅដ្ឋានរបស់ពួកគេដើម្បីបើកផ្លូវអោយទំនប់និងអាងស្តុកទឹក។ ប្រជាជនរាប់លាននាក់ទៀតដែលកំពុងរស់នៅក្នុងតំបន់ក្រោមទំនប់នោះ បានបាត់បង់ធនធាននិងជីវភាពប្រពៃណីរបស់ខ្លួន។

ការដែលធ្វើអោយបញ្ហាដែលអាក្រក់បំផុតនោះគឺ ប្រជាជនដែលទទួលរងរងការប៉ះពាល់ ពីទំនប់កម្របានអនុញ្ញាត អោយចូលរួមបញ្ចេញសំលេងនៅក្នុងការធ្វើសេចក្តីសំរេចថាតើវាគួរ ឬ មិនគួរកសាងទំនប់នោះ។ ជាធម្មតា ពួកគេមិនដឹងពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានពត៌មាននិងបញ្ចេញយោបល់ទៅសាធារណជន សិទ្ធិទាមទារដីថ្មី និងជីវភាព និងថែមទាំងមិនដឹងថាមានសិទ្ធិតវ៉ាប្រឆាំងនឹងទំនប់ទឹកទៀតផង។ ជាទូទៅពួកគេមិនបានទទួលផលពីអគ្គិសនីឬទឹក ទោះបីជាពួកគេរស់នៅជិតទំនប់ក៏ដោយ។



*កសិករខ្នាតធំកំពុងទទួលបានទឹកស្រោចស្រព និង ថាមពលពីទំនប់ ។*



*ប្រជាជនទទួលរងការប៉ះពាល់ពីទំនប់ ជាញឹកញាប់មិនទទួលបានផលចំណេញទាំងនេះទេ ហើយត្រូវរស់នៅលើដីដែលជីវជាតិអន់បំផុតទៀតផង ។*




*ទំនប់វារីអគ្គិសនីខ្លះបង្កអោយមានគ្រោះទឹកជំនន់យ៉ាងអាក្រក់*

## ■ តើទំនប់វារីអគ្គិសនីបំពេញមុខងារដោយរបៀបណា?

ក្នុងពេលដែលទំនប់អាចផ្តល់ផលចំណេញមួយចំនួន ជាញឹកញាប់ទំនប់ទាំងនេះមិនបានផលិតថាមពល ឬផ្តល់ការស្រោចស្រពអោយបានគ្រប់គ្រាន់ទៅតាមការរំពឹងទុកនោះទេ។ ការផ្គត់ផ្គង់ទឹកដែលបានមកពីទំនប់ជាញឹកញាប់ មានបរិមាណទឹកតិចជាងនូវអ្វីដែលបានសន្យា។ រឿងនេះកើតឡើងជាធម្មតា ដោយសារអ្នកកសាងទំនប់ប៉ាន់ប្រមាណលើសចំណុះទឹកដែលមានស្រាប់នៅក្នុងទន្លេ ឬ ស្ទឹងសំរាប់ប្រើប្រាស់។

ទំនប់ដែលកសាងឡើងដើម្បីគ្រប់គ្រងទឹកជំនន់ ប៉ុន្តែពួកវាអាចធ្វើអោយការខូចខាតពីទឹកជំនន់ធំៗមានលក្ខណៈកាន់តែអាក្រក់ឡើងទៅវិញ។ ប្រជាជនអាចនឹងកសាងផ្ទះនិងហាងជាច្រើននៅក្នុងតំបន់ក្រោមទំនប់ព្រោះពួកគេគិតថាមានសុវត្ថិភាព។ ទោះជាយ៉ាងណាក៏ដោយ នៅពេលទឹកជំនន់ធំកើតឡើង ហើយ

អាង ស្តុកទឹកមិនអាចទប់ទឹកបាន ប្រជាជនជាច្រើនដែលរស់នៅក្នុងតំបន់ក្រោមទំនប់ អាចនឹងបាត់បង់ទ្រព្យសម្បត្តិរបស់ខ្លួន ហើយមិនតែប៉ុណ្ណោះថែមទាំងបាត់បង់ជីវិតទៀតផង។

ទំនប់មិនគង់វង្សជារៀងរហូតនោះទេ។ គេកសាងវាឡើងជាធម្មតា គឺអោយប្រតិបត្តិការក្នុងរយៈពេលមួយ (ចំនួនឆ្នាំ) ជាក់លាក់ប៉ុណ្ណោះ។ អាយុកាលរបស់ទំនប់ ពឹងផ្អែកលើកត្តាជាច្រើន ដោយរួមទាំងបរិមាណ **កករដី** ឬ **ល្បប់** ដែលមាននៅក្នុងស្ទឹង ឬ ទន្លេ ។ នៅពេលវេលាកន្លងយូរទៅ អាងស្តុកទឹកនឹងពេញទៅដោយល្បាប់។ កាលណាល្បាប់កើនឡើងខ្ពស់ ទំនប់ក្លាយទៅជាលែងសូវមានប្រសិទ្ធិភាពរហូតដល់វាមិនអាចប្រតិបត្តិមុខងារបាន។

## ▪ អ្នកណាជាអ្នកចំណាយលុយធ្វើទំនប់វារីអគ្គិសនី?

ជារៀងរាល់ឆ្នាំថវិកាប្រមាណ ៤០ ពាន់លានដុល្លារអាមេរិកត្រូវបានគេចំណាយទៅលើទំនប់ជាច្រើន។ ដោយសារការកសាងទំនប់មានតម្លៃថ្លៃ នោះរដ្ឋាភិបាលជាធម្មតាត្រូវការខ្ចីលុយពីអ្នកផ្តល់ថវិកាជាច្រើននាក់។ ធនាគារពិភពលោកជាស្ថាប័នសំខាន់បំផុតមួយក្នុងចំណោមអ្នកផ្តល់វិកាជាច្រើនទៀត ដែលផ្តល់ថវិកាដល់ការកសាងទំនប់។ **ធនាគារអភិវឌ្ឍន៍សាធារណៈ:** មួយនេះបាននិងកំពុងចំណាយប្រាក់ ៦០ ពាន់លានដុល្លារអាមេរិកលើទំនប់ចំនួន ៦០០ កន្លែងទូទាំងពិភពលោក។ ធនាគារអភិវឌ្ឍន៍តំបន់ជាច្រើន - ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារអភិវឌ្ឍន៍ជនជាតិអាហ្វ្រិក និងធនាគារអភិវឌ្ឍន៍រវាងជនជាតិអាមេរិច - អោយលុយទៅរដ្ឋាភិបាលនិងក្រុមហ៊ុនជាច្រើនខ្ចីដើម្បីកសាងទំនប់ផងដែរ។

**នៅពេលដែលទំនប់បំពេញមុខងារមិនបានល្អ រដ្ឋាភិបាលនិងប្រជាជនជាអ្នកទទួលរងគ្រោះ**

ទំនប់ យ៉ាស៊ីរេតា (Yacyreta) បានរៀបរាប់ដោយអតីតប្រធានាធិបតីអាហ្សង់ទីន ឈ្មោះ ការឡូស មេណិម (Carlos Menem) ថា ជា "វិមានដើម្បីពុករលួយ"។ តម្លៃទំនប់បានកើនឡើងពី ២,៧ ពាន់លានដុល្លា (US$2.7 billions) ទៅ ១១,៥ ពាន់លានដុល្លារ (US&11.5 billions) ហើយគំរោងនៅតែមិនចប់រួចរាល់ទៀត។

ទំនប់ដែលស្ថិតនៅប្រទេសអាហ្សង់ទីន និង ប៉ារ៉ា ហ្គាយ ផលិតបានតែ ៦០% នៃបរិមាណអគ្គិសនីដែលវាសន្យាផលិតតែប៉ុណ្ណោះ។ ក្រុមមនុស្សដែលគ្រប់គ្រងទំនប់ជំពាក់គេរាប់ពាន់លានដុល្លារហើយមិនអាចរកលុយសងគេបានឡើយ ពីព្រោះគំរោងរកមិនបានលុយចំណេញទាល់តែសោះ។

ជាញឹកញាប់រដ្ឋាភិបាលខ្ចីលុយគេដើម្បីកសាងទំនប់ជាច្រើន។ ពួកគេរំពឹងថានឹងរកលុយបានច្រើនពីទំនប់នោះ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើទំនប់ផលិតថាមពលមិនបានច្រើន ខុសពីការរំពឹងទុក រដ្ឋាភិបាលអាចនឹងមិនមានលុយគ្រប់គ្រាន់សំរាប់សងបំណុលគេទេ។ ពួកគេអាចនឹងកាត់លុយពីថវិកាសំរាប់ការអប់រំនិងការថែទាំសុខភាព ដែលបង្កអោយមានភាពវេទនាដល់ប្រជាជនក្រីក្រទៀតផង។

ចំពោះប្រទេសដែលក្រីក្រ ការបណ្តាក់ទុនទៅលើទំនប់ដែលប្រថុយប្រថាន អាចនឹងធ្វើអោយបំណុលដែលគេជំពាក់ស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារពិភពលោកកើនឡើង។ ក្នុងករណីបែបនេះទំនប់ដែលគេកសាងឡើង ដើម្បីកាត់បន្ថយភាពក្រីក្រនោះជាក់ស្តែង គឺអាចនឹងធ្វើអោយភាពក្រីក្រកើនឡើងទៅវិញ។

នៅពេលដែលធនាគារអភិវឌ្ឍន៏សាធារណៈផ្តល់ថវិកាដល់ផ្នែកខ្លះនៃការកសាងទំនប់ វាធ្វើអោយរដ្ឋាភិបាលមានការងាយស្រួលខ្ចីលុយពីធនាគារឯកជនដែរ។ ប្រទេសអ្នកមាន ដូចជាជប៉ុន និងអាល្លឺម៉ង់ក៏មានអោយជំនួយឥតសំណង (Grant) និងប្រាក់កម្ចីទៅរដ្ឋាភិបាលជាច្រើនដែលចង់កសាងទំនប់។

ក្រោយពីគេកសាងទំនប់ហើយ រដ្ឋាភិបាលត្រូវសងប្រាក់កម្ចីទាំងនោះទៅម្ចាស់វាវិញ។ ទោះបីជាទំនប់វារីអគ្គិសនីរកលុយមិនបានច្រើនទៅតាមអ្វីដែលគេបានស្នើឡើងក៏ដោយ រដ្ឋាភិបាលនៅតែសងបំណុលគេដដែល។




*ប្រជាជននៅក្នុងប្រទេសអ្នកមានទទួលផលចំណេញពីការកសាងទំនប់តាមវិធីពីរយ៉ាង។ ក្រុមហ៊ុនកសាងទំនប់ទទួលបានលុយដើម្បីកសាងទំនប់ ហើយរដ្ឋាភិបាលទទួលបានការបង់ការប្រាក់នៅពេលដែលប្រទេសអ្នកក្រដល់ពេលសងបំណុល។*

# ជំពូក ២

# ផលប៉ះពាល់នានារបស់ទំនប់វារីអគ្គិសនី



នៅពេលដែល ម៉ាលីសិម៉េឡូ ឌីឌាន តៅ (Malisemelo Didian Tau) ឮអំពីផែនការកសាងទំនប់ផ្គត់ផ្គង់ទឹកធំមួយជាលើកដំបូង នៅលើដីរបស់នាងនៅក្នុងតំបន់ ឡិសូតូ ប្រទេសអាហ្វ្រិក នាងបានជំទាស់។ ប៉ុន្តែ អ្នកកសាងទំនប់បញ្ចុះបញ្ចូលគាត់ថា មានតែប្រជាជន តិចតួចប៉ុណ្ណោះដែលត្រូវរើចេញ ដើម្បីអោយជីវិតប្រជាជនជាច្រើននាក់បានប្រសើរឡើង។ ពួកគេបានសន្យាផ្តល់សំណងដល់ម៉ាលីសិម៉េឡូ និងសហគមន៏របស់នាង រួមនឹងការផ្គត់ផ្គង់ទឹក សាលារៀន និង ផ្ទះថ្មីៗ។

ប៉ុន្តែពួកគេមិនបានរក្សាពាក្យសន្យារបស់គេឡើយ។ ម៉ាលីសិម៉េឡូ (Malisemelo) បាននិយាយថា " នៅពេលយើងមិនបានទទួលសំណងគ្រប់គ្រាន់សំរាប់ដីរបស់យើងនោះ វាគឺជាមរណភាពនៃកូនចៅយើងនិងមរណៈភាពនៃមនុស្សជំនាន់ក្រោយ ពីព្រោះពួកគេមិនមានអ្វីសំរាប់ជួយពួកគេអោយរស់រានមានជីវិតនៅក្នុងពេលអនាគត។ "

រឿងនេះមិនមែនកើតឡើងចំពោះតែ ម៉ាលីសិម៉េឡូ (Malisemelo) តែម្នាក់ប៉ុណ្ណោះទេ មានប្រជាជនប្រហែលពី ៤០ លាន ទៅ ៨០ លាននាក់ ត្រូវបានបង្ខំអោយចាកចេញពីផ្ទះ និងដីរបស់ពួកគេដើម្បីអោយគេកសាងទំនប់។ ភាគច្រើននៃប្រជាជនទាំងនេះកាន់តែក្រទៅៗនៅពេលនេះ។ ជីវភាព វប្បធម៌ និងសហគមន៏របស់ពួកគេត្រូវបានបំផ្លាញ។

ទំនប់បានធ្វើអោយជន់លិចជំរកសត្វព្រៃសំខាន់ៗបំផុតរបស់ពិភពលោក និងដីកសិកម្មដែលមានជីវជាតិ ។ ទន្លេ ឬ ស្ទឹងត្រូវបានខូចខាត។ ជលផលត្រូវបានបំផ្លាញ។ ពូជត្រី សត្វ និង រុក្ខជាតិមួយចំនួនបាននិងកំពុងរលាយសាបសូន្យ។

ជំពូកនេះពន្យល់អំពីឥទ្ធិពលរបស់ទំនប់មកលើសហគមន៏ និងធនធានធម្មជាតិជាច្រើន។ យើងពិនិត្យមើលឥទ្ធិពលជាក់លាក់របស់ទំនប់ដែលមានមកលើគ្រួសារខ្វះលំនៅដ្ឋាននិងសហគមន៏ជាច្រើនដែលរស់នៅក្នុងតំបន់ក្រោមទំនប់។ បន្ទាប់មក យើងពិភាក្សាគ្នាអំពីអ្វីដែលសហគមន៏ជាច្រើននៅ **ឡិសូតូ** កំពុងតែធ្វើដើម្បីការពារជីវិត និងជីវភាពរបស់ខ្លួនអោយរួចផុតពីទំនប់ធំៗ។


ពួកគេប្រាប់ខ្ញុំថា ទំនប់វារីអគ្គិសនីនឹងធ្វើ
អោយជីវិតខ្ញុំប្រសើរឡើង។
ការបាត់បង់ជីវភាព
ការបាត់បង់ផ្ទះសម្បែង ទីជំរក
សុខភាពទន់ខ្សោយ

## ផលប៉ះពាល់នានារបស់ទំនប់វារីអគ្គិសនី




ទំនប់សម្លាប់ត្រី និង បំផ្លាញផលផល
បរិមាណធនធានត្រីបានថយចុះនៅក្នុងតំបន់លើទំនប់ព្រោះត្រីមិនអាចផ្លាស់កន្លែងរស់នៅឆ្លងកាត់ទំនប់បាន ការប្រែប្រួលចរន្តទឹកហូរ និងគុណភាពទឹក អាចបំផ្លាញត្រីបាន។ ប្រជាជនដែលពឹងផ្អែកលើត្រីសំរាប់ធ្វើជាអាហារ និង ចំណូលនោះនឹងទទួលរងផលប៉ះពាល់។
ទំនប់ផ្តល់ទឹកនិងថាមពលទៅអ្នកមាន
ទំនប់និងអាងស្តុកទឹកយកទឹកចេញពីស្ទឹង ឬ ទន្លេដែលកសិករជនបទនិងអ្នកនេសាទធ្លាប់ប្រើប្រាស់ ។ ពួកវាបែរជាផ្តល់ទឹក និងអគ្គីសនីទៅអោយប្រជាជនដែលមានលុយដែលចំណាយលើសេវាទាំងនេះទៅវិញ
ទិន្នផលដំណាំចុះថយ
ទំនប់ ធ្វើអោយជន់លិចដីកសិកម្មដែលមានជីវជាតិល្អបំផុតមួយចំនួន និងទប់មិនអោយល្បាប់ហូរចុះទៅក្រោម ដើម្បីផ្តល់ជីវជាតិទៅអោយដំណាំ។ ទឹកដែលគេបញ្ចេញពីអាងស្តុកទឹកអាចធ្វើអោយខូចខាតច្បារដំណាំតាមច្រាំងទន្លេ ឬ ស្ទឹង។
ទំនប់អាចបញ្ចេញទឹកដែលបានទទួលរងការបំពុល ( ទឹកក្រខ្វក់)
ទឹកដែលមានគុណភាពមិនល្អធ្វើអោយមានជំងឺដល់ប្រជាជន និងសត្វពាហនៈនៅតំបន់ក្រោមទំនប់។

## សភាពពិតនៃការផ្លាស់ទីលំនៅ

### សហគមន៍ដែលផ្លាស់ទីលំនៅទទួលរងការឈឺចាប់



*ប្រជាជន ៤០-៨០ លាននាក់ត្រូវបានបង្ខំអោយរើទីលំនៅទូទាំងពិភពដោយសារតែទំនប់ ។*

ឥទ្ធិពលអាក្រក់ធំបំផុតមួយរបស់ទំនប់គឺការ **ផ្លាស់ទីលំនៅ** ដោយបង្ខំទៅលើប្រជាជនអោយពួកគេចាកចេញពីផ្ទះសម្បែងរបស់ខ្លួន ។ អាងស្តុកទឹកធ្វើអោយជន់លិចកន្លែងដែលប្រជាជនរស់នៅ ដាំដំណាំ រកត្រី និងចិញ្ចឹមសត្វពាហនៈនៅលើដីដែលគេរស់នៅអស់ជាច្រើនជំនាន់ ។ ក្រៅពីនេះ រដ្ឋាភិបាល និងអ្នកកសាងទំនប់បង្ខំអោយប្រជាជនចាកចេញពីផ្ទះសម្បែង និងដីធ្លីរបស់ពួកគេ។ ភូមិទាំងមូលត្រូវទឹកជន់លិច។

ការផ្លាស់ទីលំនៅធ្វើអោយប្រជាជនភាគច្រើនកាន់តែក្រ។ ពួកគេជួបប្រទះបញ្ហាដោយមិនអាចរកអាហារបរិភោគ និងចំណូលគ្រប់គ្រាន់សំរាប់ចិញ្ចឹមគ្រួសាររបស់ពួកគេ។ ពួកគេអាចនឹងលែងចិញ្ចឹមខ្លួនរស់ដោយសារកសិកម្ម និងនេសាទត្រីតទៅទៀត។ សហគមន៍ជនបទអាចនឹងត្រូវបង្ខំអោយផ្លាស់ទៅទីក្រុងធំៗ ឬ ក្រុងតូចៗ ដែលពួកគេត្រូវតែសម្របខ្លួនតាមវិធីរស់នៅថ្មី។ នៅទីក្រុងធំៗពួកគេអាចនឹងប្រឈមមុខនឹងបញ្ហាដូចជាឧក្រិដ្ឋកម្ម ឬថ្នាំញៀន។

ការផ្លាស់ទីលំនៅបំផ្លាញសហគមន៍និងវប្បធម៌។ អ្នកភូមិជាញឹកញាប់ត្រូវបែងចែកជាផ្នែកៗ និងបំបែកចេញពីគ្នា ដូច្នេះហើយប្រជាជនមិនអាចរស់នៅជិតមិត្តភក្តិនិងសាច់ញាតិទៀតហើយ។ ប្រជាជនដើម និងជនជាតិភាគតិច ជាញឹកញាប់ក្លាយជាជនរងគ្រោះរបស់កសាងទំនប់។ តំបន់វប្បធម៌ និងផ្នូរបុព្វបុរស អាចនឹងរងការជន់លិចដែរ។ ប្រជាជនអាចនឹងបាត់បង់ទំនាក់ទំនងជាមួយនឹងទឹកដីដូនតារបស់ខ្លួន។



*មនុស្សដែលផ្លាស់ទីលំនៅដោយសារទំនប់មួយចំនួនត្រូវបានចូលទៅរស់នៅលើដីដែល មិនមានជីវជាតិ ឬ រឹងពិបាកដាំដុះ ។*

ជនជាតិភាគតិចម្នាក់ឈ្មោះនីយ៉ា ហឿន (Nya Heun) និយាយថា គេបានបង្ខំមនុស្សអោយចាកចេញពីផ្ទះសម្បែង ដើម្បីកសាងទំនប់ ហួយ ហូរ (Houay Ho) នៅប្រទេសឡាវ មនុស្សមួយចំនួនបានគិតថា ពួកគេអាច

នឹងធ្លាក់ខ្លួនឈឺ ប្រសិនបើពួកគេផ្លាស់ទីលំនៅ។ វាដូចជាផ្លាស់ទីលំនៅទៅប្រទេសផ្សេងអញ្ចឹង។ ទឹកចិត្តរបស់យើងចំពោះកន្លែង ទឹកចិត្តយើងចំពោះផ្ទះសម្បែង ត្រូវបានបំផ្លាញ ។"

ប្រជាជនដែលទទួលរងការប៉ះពាល់ពីទំនប់ ជាញឹកញាប់ទទួលរងបញ្ហាជាច្រើនទាំងផ្លូវចិត្តនិងផ្លូវកាយ ។ ការញៀនសុរា ការធ្លាក់ទឹកចិត្ត ហឹង្សាក្នុងគ្រួសារ ជំងឺ ហើយថែមទាំងមានការកើនឡើងនូវករណីអត្តឃាតទៀតផង បន្ទាប់ពីពួកគេបានផ្លាស់ទីលំនៅ។

## បញ្ហាដែលកើតឡើងជាមួយនឹងការតាំងលំនៅសារជាថ្មី

ប្រជាជនមួយចំនួនដែលបានផ្លាស់ទីលំនៅដោយសារតែទំនប់ ត្រូវបានគេប្រគល់ផ្ទះថ្មីអោយ។ ការប្រគល់ផ្ទះថ្មីអោយបែបនេះ ហៅថា **ការតាំងទីលំនៅសារជាថ្មី** ។ ប្រជាជនអាចនឹងត្រូវផ្លាស់ទៅភូមិដែលមានស្រាប់ ឬ ទៅភូមិដែលបង្កើតថ្មីសំរាប់តែប្រជាជនដែលរងការប៉ះពាល់ពីទំនប់ទឹក។

ជាញឹកញាប់ អ្នកកសាងទំនប់សន្យាថា ជីវភាពរបស់ប្រជាជននឹងបានប្រសើរជាងមុនបន្ទាប់ពីបានតាំងទីលំនៅសារជាថ្មី។ ពួកគេសន្យាថា ប្រជាជននឹងមានការងារជាច្រើនធ្វើ និង ផ្ទះថ្មីធំៗរស់នៅ ជាមួយនឹងអគ្គិសនី និង ទឹក។ ទោះជាយ៉ាងណាក៏ដោយ ប្រជាជនមិនអាចរកលុយបង់ថ្លៃអគ្គិសនីនិងទឹកបានឡើយ ។ ជាធម្មតាពួកគេបានទទួលដីតូចជាងដីដែលពួកគេធ្លាប់មានពីមុន។ ដីថ្មីដែលទទួលបានអាចនឹងពិបាកធ្វើកសិ-ដ្ឋានជាងដីចាស់របស់ពួកគេ។

ប្រជាជនដែលបានតាំងទីលំនៅសារជាថ្មីមិនអាចធ្វើកសិដ្ឋាន ឬ នេសាទ ឬ ចិញ្ចឹមបសុសត្វដូចដែលពួកគេធ្លាប់ធ្វើពីមុនមក បានទេ។ ពេលខ្លះ អ្នកកសាងទំនប់ជំរុញអោយពួកគេទទួលយកជីវភាពថ្មី ដូចជា ការដាំស្មៅអោយសត្វស៊ី ឬ ដាំដំណាំដើម្បីលក់នៅទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើបែបនេះ ជាធម្មតាមិនបានទទួលជោគជ័យទេ ហើយប្រជាជនអាចនឹងជួបពេលវេលាពិបាកចិញ្ចឹមជីវិតជាងមុនទៀតផង។

## ប្រជាជនជាច្រើនមិនបានទទួលសំណងគ្រប់គ្រាន់

**សំណង** គឺជាលុយ ឬវត្ថុផ្សេងទៀតដែលគេផ្តល់អោយដើម្បីជំនួសអ្វីដែលប្រជាជនបានបាត់បង់។ នៅពេលណាគេផ្តល់សំណងជាប្រាក់ដល់ប្រជាជន ជាញឹកញាប់ជាលុយដែលមានចំនួនមិនគ្រប់គ្រាន់ដែលអាចអោយពួកគេរស់បាន ។ ប្រសិនបើប្រជាជនមិនចេះគ្រប់គ្រងប្រាក់ ពួកគេ




*បើគ្មានអាហារ ឬលុយគ្រប់គ្រាន់ទេ គ្រួសារជាច្រើនជាញឹកញាប់ ចប់ដោយការរស់នៅក្នុងតំបន់អាណាធិបតេយ្យ ឬធ្វើការជាកម្មករចំណាកស្រុក។*

អាចនឹងមិនដឹងពីរបៀបធ្វើអោយលុយនៅគង់វង្សបានយូរឡើយ ។

មានប្រជាជនច្រើននាក់ណាស់ដែលមិនបានទទួលសំណង ។ រដ្ឋាភិបាលអាចនឹងនិយាយថា ប្រជាជនមិនមានសិទ្ធិទទួលបានសំណងឡើយ ពីព្រោះពួកគេមិនមានកម្មសិទ្ធិស្របច្បាប់លើដីដែលពួកគេកំពុងរស់នៅនោះទេ។ សហគមន៍ជាច្រើនអាចនឹងចែកដីគ្នារស់នៅ ឬប្រជាជនមួយចំនួន អាចនឹងធ្វើកសិដ្ឋានលើដីដែលជាកម្មសិទ្ធិរបស់អ្នកផ្សេង។ ឬរដ្ឋាភិបាលអាចនឹងមិនគិតថា ប្រជាជននឹងទទួលរងការប៉ះពាល់ពីទំនប់ឡើយ ។

" មន្ត្រីរដ្ឋាភិបាលជាច្រើនបានប្រាប់យើង " បោះបង់ផ្ទះតូចរបស់អ្នកចោលទៅសំរាប់ផលប្រយោជន៍ផ្ទះធំ (ជាតិ) " ហ្សាង យ្យូ ឡៅ (Zhang Qiu Lau) បានឧទ្ទានឡើង។ គាត់ជាមនុស្សម្នាក់ដែលបានតាំងទីលំនៅសារជាថ្មីដោយសារទំនប់ ហ្សៅ អៅ ឡាងឌី (Xiaolangdi) នៅប្រទេសចិន។ " ពួកគេបានសន្យាចំណាយ ១៥ សេនក្នុងដីទំហំ ៣០, ៤៨ ស.ម² សំរាប់ផ្ទះរបស់យើង និងរកដីកសិដ្ឋានអោយយើងទៅតាមទំហំដីដែលយើងមានទាំងអស់។ ប៉ុន្តែរហូតមកដល់ពេលនេះ ខ្ញុំមិនបានទទួលអ្វីទេ គ្មានលុយ ហើយគ្រួសាររបស់យើងដែលមានដីកសិដ្ឋានសំបូរជីជាតិទំហំកន្លះអាក្រក្នុងមនុស្សម្នាក់នោះ ទទួលបានតែដីពាក់កណ្តាលដែលជាដីខ្សោះជីជាតិខ្លាំង នៅពេលយើងបានផ្លាស់មករស់នៅឯ ហ្សៀង យួន (Xiang Yuan) ។"

## ■ ប្រជាជនរាប់លាននាក់រងការប៉ះពាល់នៅតំបន់ក្រោមទំនប់វារីអគ្គីសនី

ទំនប់បាននិងកំពុងបំផ្លាញជីវភាពរបស់ប្រជាជនរាប់លាននាក់ដែលរស់នៅក្នុងតំបន់ក្រោមទំនប់។ ឥទ្ធិពល អាក្រក់ធំបំផុតគឺទៅលើការនេសាទ និង ការធ្វើកសិកម្ម។



*ត្រីដែលគេចាប់បាននៅតំបន់ក្រោមទំនប់ថយចុះ ៦០ ភាគរយ បន្ទាប់ពីការសាងសង់ទំនប់ **ទូគូរូអុិ** របស់ប្រទេសប្រេស៊ីល។ មានមនុស្សតិចតួចប៉ុណ្ណោះដែលនេសាទសព្វថ្ងៃនេះ។*

### ធនធានជលផលត្រូវបានបំផ្លាញ

ទំនប់ បានបំផ្លាញវិស័យជលផលដោយការធ្វើអោយចរន្តទឹកប្រែប្រួល និងរាំងត្រីមិនអោយទៅដល់តំបន់ពងកូន និងជម្រក **នៅតំបន់ផ្នែកខាងលើ** របស់ទំនប់។ អ្នកនេសាទត្រី ជាធម្មតាមានចំនួនថយចុះ។ ពូជត្រីខ្លះរលាយផុតពូជ។ ជាលទ្ធផល ប្រជាជន អាចនឹងបាត់បង់ប្រភពសំខាន់នៃប្រូតេអុីន និងចំណូល។ ជីវិតប្រពៃណីរបស់ពួកគេអាចនឹងត្រូវបំផ្លាញដូចគ្នាដែរ។

### ដំណាំថយចុះ

ប្រជាជនអាចរងការឈឺចាប់ ដោយសារការខូចខាតចំពោះដំណាំរបស់ខ្លួន ។ ការប្រែប្រួលចំពោះចរន្តទឹកហូរអាចច្រោះដីច្រាំងទន្លេ ឬស្ទឹង។ ពេលខ្លះច្បារដំណាំ ដី និង ដំណាំរបស់ប្រជាជនរស់នៅតាមមាត់ស្ទឹងឬទន្លេត្រូវបានបាក់ធ្លាក់ចូលក្នុងស្ទឹងឬទន្លេដោយសារទឹក។

ទន្លេឬស្ទឹងនាំយកមកនូវជីជាតិ និងល្បាប់ដែលបង្កើតជាទីវាលសំបូរជីជាតិក្រោយពីទឹកជំនន់។ ទំនប់បញ្ឈប់ជីជាតិនិងល្បាប់ទាំងនេះមិនអោយហូរទៅតំបន់ក្រោមទំនប់។ បើគ្មានជីជាតិទាំងនេះទេផលដំណាំ អាចនឹងថយចុះ។ ប្រជាជនអាចត្រូវទិញជីគីមី។ ប្រសិនបើជីគីមីនេះថ្លៃពេក ប្រជាជនអាចនឹងឈប់ធ្វើ កសិកម្ម។



*បន្ទាប់ពីទំនប់ **យ៉ាលី ហ្វាល** ត្រូវបានកសាងរួច។ អ្នកភូមិកម្ពុជាជាច្រើនឈឺឬរមាស់ស្បែក ប្រសិនបើពួកគេងូតទឹកនៅក្នុងទន្លេសេ សាន។*

### ខ្វះទឹកស្អាតប្រើប្រាស់

ជាញឹកញាប់ទឹកអាចទៅជាក្រខ្វក់ ឬ ទទួលរងការបំពុលនៅផ្នែកខាងក្រោមទំនប់។ ប្រជាជននិងសត្វអាចនឹងមានជំងឺប្រសិនបើពួកគេផឹកទឹក ជាពិសេសក្នុងពេលដែលទឹកហូតិច។ ប្រជាជនអាចនឹងឈឺ ឬ

រមាស់ស្បែក ងូតទឹកក្នុងស្ទឹងឬទន្លេ ហើយអាចមានទឹកតិចតួចសំរាប់ស្រោចស្រពដំណាំ។

**ការបញ្ចេញទឹកបន្ទាន់បណ្តាលអោយមានការខូចខាត**

ប្រតិបត្តិករទំនប់ទឹក ពេលខ្លះសំរេចចិត្តបើកទឹកបន្ទាន់ចេញពីអាងស្តុកទឹក។ កំរិតទឹកអាចកើនឡើងយ៉ាងលឿន។ ប្រជាជន ដែលប្រើប្រាស់ទន្លេ ឬ ស្ទឹងអាចនឹងមិនបានទទួលការប្រកាសប្រាប់ជាមុនទេ។ ទូក និងឧបករណ៍នេសាទរបស់ពួកគេអាចនឹងរសាត់បាត់ទៅតាមទឹកឡើងនោះ។ ក្នុងករណីមួយចំនួន ប្រជាជនអាចនឹងលង់ទឹកស្លាប់ផងដែរ។

**សហគមន៍ប្រយុទ្ធប្រឆាំងនឹងភាក្រីក្រនៅក្នុងតំបន់ ឡិសូតូ** (Lesotho)



មុនទំនប់ **កាតសិ** ត្រូវបានកសាងហើយនៅក្នុងតំបន់ **ឡិសូតូ** សហគមន៍មូលដ្ឋានអាចដាំដុះដំណាំជាច្រើនពេញមួយឆ្នាំៗ។ ពួកគេដាំល្ពៅ សណ្តែកបារាំង សណ្តែកធម្មតា ដំឡូង និង បន្លែផ្សេងៗទៀត ។ ចំការដ៏ធំរបស់ពួកគេអាចផលិតអាហារគ្រប់គ្រាន់សំរាប់ចែករំលែកជាមួយអ្នកដទៃ។

ប៉ុន្តែក្រោយពីពួកគេបានតាំងទីលំនៅថ្មីមក សហគមន៍ជាច្រើនកាន់តែក្រទៅៗ។ ពាក្យសន្យាផ្តល់សំណងនិងជីវភាពថ្មីត្រូវបានបំភ្លេច។ ប្រជាជនខ្លះបានស្លាប់។

" ជីវិតនៅទីនេះ លើតំបន់តាំងទីលំនៅសារជាថ្មីគឺមានការពិបាក។ យើងតស៊ូយ៉ាងលំបាក ដើម្បីអោយបានអ្វីៗគ្រប់យ៉ាង រួមទាំងបន្លែដែលដុះតាមធម្មជាតិ។ នៅឯ ម៉ូលីកាលីកូ យើងមានអាហារពេញមួយឆ្នាំៗ។ នៅទីនេះ យើងជួបទុរ្ភិក្សពេញមួយឆ្នាំៗ " តាមសម្តីរបស់ Nkhono Maseipati ដែលបានតាំងទីលំនៅសារជាថ្មីដោយសារទំនប់ កាតសិ។

សហគមន៍ជាច្រើននៅក្នុងតំបន់ ឡិសូតូ គឺកំពុងប្រយុទ្ធប្រឆាំងដើម្បីអោយមានការសងសំណងដែលយុត្តិធម៌។ ពួកគេបានដាក់ពាក្យបណ្តឹងជាមួយនឹងអ្នកកសាងទំនប់ ប្រាប់សាធារណៈជនអោយបានដឹងពីកង្វល់របស់ខ្លួននិងបានរៀបចំបាតុកម្ម។ នៅចុងឆ្នាំ ២០០៥ មន្ត្រីរដ្ឋាភិបាលម្នាក់បានសន្យាចំពោះសហគមន៍ថាផ្តល់អោយពួកគេនូវអ្វីៗដែលពួកគេទាមទារ។ តើគេធ្វើតាមពាក្យសន្យាថ្មីទាំងនេះឬទេ?

ប្រសិនបើអ្នកលឺថា គេអាចនឹងសង់ទំនប់មួយនៅក្នុងតំបន់របស់អ្នក កត្តាសំខាន់គឺត្រូវចងចាំរឿងដូចនេះ។ គិតដល់ការប្រែប្រួលដែលកើតចំពោះជីវិតរបស់អ្នកនឹងមានលក្ខណៈយ៉ាងណា ប្រសិនបើទំនប់ត្រូវបានសង់នៅជិតៗនោះ។ ចូរស្រមៃអំពីរបៀបដែលវាអាចប៉ះពាល់ដល់គ្រួសារ ជីវភាព វប្បធមិ និងសហគមន៏របស់អ្នក។

## សំណួរសំរាប់ការពិភាក្សា



# ជំពូក ៣

# ចលនាអន្តរជាតិប្រឆាំងនឹងទំនប់ដែលផ្តល់ផលប៉ះពាល់




ប្រជាជនរាប់លាននាក់ជុំវិញពិភពលោក ប្រយុទ្ធប្រឆាំងនឹងទំនប់ដែលផ្តល់ផលប៉ះពាល់។អ្នកនេសាទនៅក្នុងប្រទេស ប៉ាគីស្ថាន កសិករនៅក្នុងប្រទេសថៃ និង ប្រជាជនដើមនៅក្នុងប្រទេស ហ្គាតេម៉ាឡា នាំគ្នាប្រឆាំងនឹងទំនប់។ សាស្ត្រាចារ្យមហាវិទ្យាល័យក្នុងប្រទេសជប៉ុន និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដែលធ្វើការអំពីសិទ្ធិមនុស្សនៅក្នុងប្រទេសអ៊ូហ្គានដាក៏នាំគ្នាប្រឆាំងនឹងទំនប់ដែរ។ ពួកគេប្រយុទ្ធដើម្បីការពារជីវភាពរបស់ប្រជាជននិងធនធានធម្មជាតិ ហើយពួកគេប្រឆាំងដើម្បីសិទ្ធិរបស់ប្រជាជនអោយមានការចូលរួមនៅក្នុងការសំរេចចិត្តផ្សេងៗដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។

ការខំប្រឹងប្រែងទាំងនេះ គឺកាន់តែមានប្រសិទ្ធភាពថែមទៀតនៅពេលណាប្រជាជនធ្វើការរួមគ្នាជាសម្ព័ន្ធប្រចាំតំបន់ និង សម្ព័ន្ធអន្តរជាតិ។ បច្ចុប្បន្ននេះ មានបណ្តាញអ្នកប្រឆាំងនឹងទំនប់ជាច្រើននៅក្នុងតំបន់អាមេរិកឡាទីន អាស៊ីខាងកើតនិងអគ្នេយ៍ អាស៊ីខាងត្បូង អឺរ៉ុបនិងអាហ្វ្រិក (សូមមើលផ្នែកអំពី *ទំនាក់ទំនងប្រចាំតំបន់* សំរាប់ពតិមានបន្ថែមទៀត)។ បណ្តាញទាំងនេះគឺរួមបញ្ចូលទាំងប្រជាជនដែលរងការប៉ះពាល់ពីទំនប់ចលនាប្រជាជន អង្គការមិនមែនរដ្ឋាភិបាលនានា អ្នកសិក្សាស្រាវជ្រាវ និងក្រុមដទៃទៀត។ ប្រជាជនប្រើបណ្តាញទាំងនេះដើម្បីចែករំលែកព័តិមានអោយគ្នា រៀបចំសកម្មភាពរួម និងធ្វើការរួមគ្នាដើម្បីបញ្ឈប់ទំនប់និងការពារសិទ្ធិមនុស្សចាំបាច់របស់ប្រជាជន។

អ្នកប្រឆាំងនឹងទំនប់បានរៀបចំកិច្ចប្រជុំអន្តរជាតិចំនួនពីរដើម្បីចែករំលែកបទពិសោធន៍និងបង្កើតយុទ្ធសាស្ត្រផ្សេងៗដើម្បីប្រឆាំងនឹងទំនប់ដែលមានលក្ខណៈបំផ្លាញ។ ក្នុងឆ្នាំ ១៩៩៧ អ្នកចូលរួមជាច្រើនមកពីប្រទេសចំនួន ២០ បានជួបគ្នាក្នុងប្រទេសប្រេស៊ីល។ កិច្ចប្រជុំទីពីរបានប្រារព្ធឡើងនៅក្នុងឆ្នាំ ២០០៣ នៅប្រទេសថៃ ដោយមានអ្នកចូលរួមចំនួន ៣០០ នាក់ មកពីប្រទេសចំនួន ៦១។ ចលនានេះ បន្តលូតលាស់និងមានកម្លាំងកាន់តែខ្លាំងឡើង។

## ■ ភាពជោគជ័យរបស់អ្នកប្រឆាំងនឹងទំនប់



### ទំនប់ចំនួនតិចតួចដែលកំពុងសាងសង់

ចលនាអន្តរជាតិបានទទួលជោគជ័យនៅក្នុងការបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនី។ ឥឡូវនេះ ទំនប់វារីអគ្គិសនីដែលកំពុងសាងសង់ មានចំនួនតិចជាងចំនួននៅក្នុងអតីតកាល ព្រោះមានការប្រឆាំងខ្លាំងទល់នឹងទំនប់។ រដ្ឋាភិបាលថៃមទាំងបានលប់ចោល គំរោងជាច្រើនទៀតផង។



### ទំនប់វារីអគ្គិសនីមួយចំនួនត្រូវបានកំទេចចោល

បច្ចុប្បន្ននេះ នៅក្នុងសហរដ្ឋអាមេរិកនិងអឺរ៉ុប ទំនប់ជាច្រើនដែលត្រូវបានសាងសាងជាច្រើនឆ្នាំកន្លងទៅនោះ គឺកំពុងត្រូវបាន **បញ្ឈប់ដំណើរការ** ឬកំទេចចោល។ ទន្លេ ឬ ស្ទឹងត្រឡប់មករកជីវិតធម្មជាតិសារជាថ្មីវិញ។ នៅក្នុងប្រទេសបារាំង ទំនប់តូចៗជា ច្រើននៅលើទន្លេ ឡ័រ (Loire) និង ឡែកែរ (Leguer) គឺត្រូវបញ្ឈប់ដំណើរការជា ច្រើនឆ្នាំកន្លងទៅថ្មីៗនេះ។ បន្ទាប់ពីទំនប់ត្រូវបានគេកំទេចចោលមក ទន្លេឬស្ទឹងបានត្រឡប់មករកជីវិតធម្មជាតិរបស់វាវិញ។ ត្រីសាលមន់ និងប្រភេទត្រីផ្សេងទៀតបានចាប់ផ្តើមហែលឡើងចុះតាមទន្លេឬស្ទឹងម្តងទៀត។



### សិទ្ធិរបស់ប្រជាជនដែលរងទទួលការប៉ះពាល់ត្រូវបានលើកស្ទួយ

ប្រជាជនដែលរងទទួលការប៉ះពាល់ពីទំនប់ជាច្រើននាក់ បានប្រឆាំងដោយជោគជ័យ ដើម្បីការពារសិទ្ធិរបស់ពួកគេ។ ប្រជាជនខ្លះបានទទួលសំណងប្រសើរជាងមុន។ មួយចំនួនទៀតបានចូលរួមក្នុងដំណើរការនៃការសំរេចិត្ត ហើយខ្លះទៀតបានទទួលទឹកសំរាប់ស្រោចស្រពនិងអគ្គីសនី។

ដោយសារតែការតវ៉ាពីប្រជាជនដែលរងការប៉ះពាល់ និងសម្ព័ន្ធដៃគូរបស់ពួកគេ ឥឡូវនេះមានគោលការណ៍ណែនាំអន្តរជាតិអំពីការធ្វើអោយការសាងសង់ទំនប់មានលក្ខណៈប្រសើរឡើងជាងមុន។ គោលការណ៍ណែនាំនេះត្រូវបានបង្កើតឡើងដោយ គណៈកម្មាធិការពិភពលោកទទួលបន្ទុកទំនប់ទឹក (WCD)។ WCD និយាយថា គេមិនគួរសាងសង់ទំនប់ដោយគ្មានការយល់ព្រមពីប្រជាជនដែលរងការប៉ះពាល់ឡើយ។ អ្នកកសាងទំនប់គួរចុះហត្ថលេខាលើកិច្ចសន្យាស្របច្បាប់ជាមួយប្រជាជនដែលទទួលរងការប៉ះពាល់ ដោយត្រូវផ្តល់សំណងដល់ពួកគេ។ ប្រសិនបើកិច្ចសន្យាត្រូវបានគេរំលោភបំពាន ប្រជាជនដែលទទួលរងការប៉ះពាល់គួរអាចចាត់វិធានការផ្លូវច្បាប់ប្រឆាំងនឹងអ្នកកសាងទំនប់។ រដ្ឋាភិបាលជាច្រើនមិនបានអនុវត្តតាមគោលការណ៍ទាំងនេះទេ ប៉ុន្តែប្រជាជនដែលរងការប៉ះពាល់កំពុងប្រើប្រាស់គោលការណ៍ណែនាំទាំងនេះជាឧបករណ៍មួយដើម្បីប្រឆាំងទាមទារសិទ្ធិរបស់ពួកគេ។



## លុយកាន់តិចទៅៗសំរាប់ទំនប់វារីអគ្គិសនី

ទំនប់ចំណាយលុយច្រើនណាស់។ រដ្ឋាភិបាលនៅក្នុងតំបន់អាមេរិក ឡាទីន អាហ្វ្រិក និងអាស៊ីត្រូវខ្ចីលុយពីធនាគារអភិវឌ្ឍន៍សាធារណៈនិងធនាគារឯកជនដើម្បីចំណាយទៅលើទំនប់វារីអគ្គិសនីជាច្រើន។ កាលពីម្ភៃឆ្នាំមុន អ្នកផ្តល់ថវិកាទាំងនេះបានផ្តល់អោយនូវលុយជាច្រើន ដើម្បីកសាងទំនប់។ បច្ចុប្បន្ននេះ ដោយសារមានការប្រឆាំងខ្លាំងក្លាទល់នឹងទំនប់ធំៗជាច្រើន ពួកគេបានផ្តល់ប្រាក់កម្ចីចំនួនតិចតួចទៅអោយគំរោងទាំងនោះ។ ប្រការនេះបានធ្វើអោយវាកាន់តែពិបាកទៅៗសំរាប់រដ្ឋាភិបាលក្នុងការសាងសង់ទំនប់ទឹក។

## **អ្នកភូមិឈ្នះបានជោគជ័យនៅទំនប់ រ៉ាស៊ីសាឡៃ**



ក្នុងឆ្នាំ ២០០១ ទ្វារទឹកនៃទំនប់ **រ៉ាស៊ីសាឡៃ** របស់ប្រទេសថៃត្រូវបានបើកចំហជាអចិន្ត្រៃ។ នេះ គឺជាជ័យជំនះដ៏ធំសំរាប់ប្រជាជនដែលរងការប៉ះពាល់ពីទំនប់ទឹក។

ទំនប់ **រ៉ាស៊ីសាឡៃ** បានធ្វើអោយទឹកជន់លិចដីកសិដ្ឋានរបស់ប្រជាជនជាង ១៥000 នាក់ វារារាំងផ្លូវបំលាស់ទីជំរករបស់ត្រីនិងធ្វើអោយទឹកជនលិចព្រៃវាលភក់។ វាគឺជាមហន្តរាយសំរាប់មនុស្សគ្រប់រូប។ ប្រជាជនដែលរងការប៉ះពាល់បានសំរេចចិត្តប្រឆាំង។ ពួកគេបានទាមទារថា ទ្វារទឹករបស់ទំនប់ត្រូវតែបើកចំហរជាអចិន្ត្រៃដើម្បីស្តារឡើង វិញនូវទន្លេនិងជីវភាពរបស់ប្រជាជន។

ពួកគេបានបង្កើតភូមិតវ៉ាមួយនៅក្នុងតំបន់អាងស្តុកទឹកដើម្បីអោយមានការយកចិត្តទុកដាក់ ចំពោះការទាមទាររបស់ពួកគេ។ អ្នកតវ៉ាមួយចំនួនបានកាន់កាប់តំបន់ទំនប់។ ពួកគេបាននិយាយថា ពួកគេនឹងមិនចាកចេញទេ រហូតទាល់តែគេបើកទ្វារទឹករបស់ទំនប់។ ក្នុងពេលមួយនោះ អ្នកតវ៉ាត្រូវព័ទ្ធជុំវិញទៅដោយកំពស់ទឹកដែលចេះតែកើនឡើង។ ការតវ៉ានេះប្រព្រឹត្តិទៅអស់ជាច្រើនឆ្នាំ ។

នៅទីបញ្ចប់ អ្នកភូមិបានទទួលជ័យជំនះ។ រដ្ឋាភិបាលថៃបានយល់ព្រមបើកទ្វារទឹករបស់ទំនប់។ ចាប់តាំងពីពេលនោះមក ទន្លេ ម៉ូន បានត្រឡប់មករកសភាពដើមវិញ។ ជាថ្មីម្តងទៀត ប្រជាជនអាចដាំដុះដំណាំនៅលើច្រាំងទន្លេនិងចាប់ត្រី។ ពួកគេបានទទួលមកវិញនូវជីវភាពរបស់ខ្លួន។

**បុញ្ញា គង់ចាម** អ្នកដឹកនាំរបស់ចលនា "រ៉ាស៊ីសាឡៃ បានពន្យល់អំពីហេតុអ្វីបានជានាងប្រឆាំង ដើម្បីបញ្ឈប់ដំណើរការរបស់ទំនប់ : " ការសង្គ្រោះបរិស្ថានគឺជាវិធីតែមួយគត់ដើម្បីជួយដល់កូនចៅរបស់ខ្ញុំនៅក្នុងពេលអនាគតដ៏វែងឆ្ងាយ។ នោះហើយគឺជាអ្វីដែលខ្ញុំកំពុងធ្វើនៅពេលនេះ។ "

## ■ ភាពជោគជ័យ...ប៉ុន្តែទំនប់នៅតែគំរាមកំហែងសហគមន៍ជាច្រើន

ទាំងនេះគឺជាជោគជ័យដ៏ធំ ប៉ុន្តែនៅមានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ។ នៅក្នុងប្រទេសជាច្រើនជុំវិញពិភពលោក រដ្ឋាភិបាលគឺនៅតែកំពុងសាងសង់ទំនប់បំផ្លាញជាច្រើន។ ប្រជាជនជាច្រើននាក់ នៅតែបាត់បង់ផ្ទះសម្បែង និងដីធ្លីដោយសារតែទំនប់និងអាងស្តុកទឹកនៅឡើយ។ រដ្ឋាភិបាលដែលមានអំណាច ធនាគារក្រុមហ៊ុននិងធនាគារអភិវឌ្ឍន៏ជាច្រើនមានផែនការធំៗដើម្បីការកសាងទំនប់ច្រើនថែមទៀត។

- យើងត្រូវការពង្រឹងកម្លាំងប្រឆាំងនឹងទំនប់បំផ្លាញ។
- យើងត្រូវការធ្វើការរួមគ្នា គាំទ្រគ្នា និងរៀនសូត្រពីគ្នាទៅវិញមកដើម្បីការពារសិទ្ធិរបស់ប្រជាជនដែលរងការប៉ះពាល់ពីទំនប់ទឹក។

នៅពេលដែលមានប្រជាជនជាច្រើនប្រឆាំងរួមគ្នាទល់នឹងទំនប់ វាគឺកាន់តែពិបាកសំរាប់រដ្ឋាភិបាល និងក្រុមហ៊ុនក្នុងការកសាងទំនប់និងបង្កគ្រោះភ័យដល់សហគមន៏។

# ជំពូក ៤

# វិធីសាស្ត្រក្នុងការប្រឆាំងនឹងទំនប់

អ្នកអាចធ្វើរឿងជាច្រើនដើម្បីប្រឆាំងនឹងទំនប់និងដើម្បីប្រឆាំងទាមទារសិទ្ធិរបស់អ្នក។ ជំហានទីមួយគឺត្រូវប្រមូលព័ត៌មានអំពីទំនប់ និងឥទ្ធិពលអាក្រក់បែបណាដែលវាអាចមានមកលើសហគមន៍របស់អ្នក។ បន្ទាប់មកទៀត អ្នកគួរប្រមើលមើលអ្វីខ្លះដែលអ្នកចង់បាននិងវិធីសាស្ត្រដែលអ្នកអាចធ្វើអោយអ្វីដែលអ្នកចង់បានកើតឡើង។ បន្ទាប់មកអ្នកចាត់វិធានការដើម្បីសំរេចឱ្យបានគោលដៅរបស់អ្នក។ ដំណើរការនេះជាញឹកញាប់គេហៅថា **យុទ្ធនាការ**។

ចំណុចសំខាន់គឺត្រូវចាប់ផ្តើមយុទ្ធនាការរបស់អ្នកអោយបានឆាប់តាមតែអាចធ្វើបាន។ សកម្មភាពសំខាន់ៗមួយចំនួនដែលអ្នកអាចធ្វើបាននៅក្នុងយុទ្ធនាការតាំងពីដើមរហូតដល់ចប់ គឺរួមទាំងប្រមូលនិងចែកចាយព័ត៌មាន រៀបចំជាមួយអ្នកដទៃនៅក្នុងសហគមន៍របស់អ្នក និងធ្វើការរួមគ្នាជាមួយក្រុមក្នុងប្រទេស ក្រុមក្នុងតំបន់ និងក្រុមអន្តរជាតិ។

នៅក្នុងប្រទេសមួយចំនួន ការចងក្រងគ្នាដើម្បីប្រឆាំងនឹងទំនប់អាចមានគ្រោះថ្នាក់ខ្លាំងណាស់សំរាប់សមាជិកសគមន៍និងក្រុមគ្រួសាររបស់ពួកគេ។ នៅពេលខ្លះ វាគឺជាការប្រថុយប្រថានក្នុងរិះគន់រដ្ឋាភិបាល ឬផែនការកសាងទំនប់។ រឿងសំខាន់គឺត្រូវដឹងអំពីហានិភ័យទាំងនេះ នៅពេលអ្នកបង្កើតយុទ្ធនាការរបស់អ្នក។

ជំពូកនេះផ្តល់អោយអ្នកនូវយោបល់ផ្សេងៗអំពីវិធីសាស្ត្រក្នុងការបង្កើតយុទ្ធសាស្ត្រនៃយុទ្ធនារការ។ ជំពូកនេះនឹងដាក់ចេញជាគ្រោងសកម្មភាពធំៗ ដែលអ្នកអាចធ្វើឡើងនៅក្នុងដំណើរការសាងសង់ទំនប់ពីដើមដល់ចប់។ នៅទីបញ្ចប់ វាអធិប្បាយអំពីជំហានទាំងបីនៃការកសាងទំនប់ និងកំណត់ជំហានសំខាន់ៗដែលអ្នកអាចធ្វើបាននៅក្នុងជំហាននីមួយៗ។




*ខែមិនា ថ្ងៃទី១៤ គឺជាទិវាអន្តរជាតិសំរាប់សកម្មភាពប្រឆាំងនឹងទំនប់និងសំរាប់ទន្លេឬស្ទឹង ទឹក និង ជីវិត។ មនុស្សរាប់រយក្រុមនៅជុំវិញពិភពលោក ចាត់វិធានការដើម្បីធ្វើបាតុកម្មប្រឆាំងនឹងទំនប់បំផ្លាញ អបអរជ័យជំនះនិងអប់រំសាធារណៈជន។ ដោយការរៀបចំសកម្មភាពនៅថ្ងៃទី ១៤ មិនា អ្នកអាចបង្កើនការយល់ដឹងរបស់សាធារណៈជនអំពីការតស៊ូរបស់អ្នកនិងការប្រឆាំងជាអន្តរជាតិចំពោះទំនប់ធំៗ។*

## ■ រៀបចំផែនការយុទ្ធនាការរបស់អ្នក

### ១. ការប្រមូលព័ត៌មាន

កត្តាសំខាន់គឺត្រូវយល់អោយបានច្បាស់អំពីរបៀបបែបបទដែលទំនប់អាចមានឥទ្ធិពលអាក្រក់មកលើសហគមន៍របស់អ្នក និងទន្លេឬស្ទឹង។ អ្នកអាចប្រើ **អង្កេតមូលដ្ឋាន** ដើម្បីប្រមូលព័ត៌មានពីសមាជិករបស់សហគមន៍អ្នក អង្គការមិនមែនរដ្ឋាភិបាលនានា អ្នកសិក្សាស្រាវជ្រាវរបស់មហាវិទ្យាល័យ និងក្រុមមនុស្សផ្សេងទៀតក៏អាចជួយអ្នកបានដែរ។ នៅទីនេះមាន សំណួរមួយចំនួនសំរាប់យកទៅពិចារណា:

- តើភូមិមួយណា និង ដីត្រង់ណាដែលនឹងទទួលរងការប៉ះពាល់ពីទំនប់និងអាងស្តុកទឹក?
- តើមានប្រជាជនប៉ុន្មាននាក់ដែលនឹងត្រូវរើចេញ?

- តើមានប្រជាជនប៉ុន្មាននាក់ដែលនឹងបាត់បង់តំបន់នេសាទនិងដីកសិកម្មរបស់ពួកគេ?
- តើដីនោះមានតម្លៃដូចម្តេច ដំណាំ ផ្ទះសម្បែង និង/ឬ បរិមាណត្រីដែលអាចចាប់បានដែលនឹងត្រូវបាត់បង់?
- តើគេកំពុងផ្តល់អោយនូវសំណងនិងការតាំងទីលំនៅសារជាថ្មីបែបណា?
- អ្នកណាជាអ្នកកំពុងកសាងទំនប់? តើវាជារដ្ឋាភិបាល ក្រុមហ៊ុនឯកជន ឬក៏ទាំងពីរ?
- អ្នកណាជាអ្នកចេញលុយកសាងទំនប់?

## ២. តើអ្នកគោលដៅយ៉ាងណាខ្លះ?




ជំហានបន្ទាប់មកទៀតសំរាប់រៀបចំយុទ្ធនាការរបស់អ្នកគឺត្រូវកំណត់គោលដៅរបស់អ្នកនិងបង្កើតយុទ្ធសាស្ត្រមួយដើម្បីសំរេចតាមគោលដៅរបស់អ្នក។ នៅទីនេះមានរឿងមួយចំនួនសំរាប់ពិចារណា:

- តើអ្វីដែលអ្នកព្យាយាមធ្វើអោយបានសំរេច?
- តើអ្នកចង់បញ្ឈប់ទំនប់ឬទេ?
- តើអ្នកចង់បានសំណងដែលល្អជាងធម្មតាឬទេ?
- តើអ្នកចង់មានសំលេងនៅក្នុងការសំរេចចិត្តអំពីទំនប់ដែលបង្កការប៉ះពាល់ដល់សហគមន៍របស់អ្នកដែរឬទេ?

ត្រូវប្រាកដថា អ្នកបានចែករំលែកគោលដៅរបស់អ្នកជាមួយសមាជិកនៃសហគមន៍របស់អ្នកបានដឹង។ គោលដៅរបស់អ្នកអាចនឹងប្រែក្លាយទៅជាការទាមទារសំរាប់ការធ្វើយុទ្ធនាការរបស់អ្នកបាន។ ឧទាហរណ៍ " បញ្ឈប់ទំនប់ អូការ៉ាំងហ្គោ " ឬ " ត្រូវមានសំណងច្រើនថែមទៀតសំរាប់សហគមន៍ អូការ៉ាំងហ្គោ ! " ។

## ៣. អ្នកណាជាសម្ព័ន្ធមិត្តរបស់អ្នក ហើយអ្នកជាអ្នកប្រឆាំងនឹងអ្នក?

ការកសាងសម្ព័ន្ធមិត្តគឺជាផ្នែកសំខាន់មួយក្នុងចំណោមផ្នែកសំខាន់ជាច្រើននៃយុទ្ធសាស្ត្រធ្វើយុទ្ធនាការ ។ ចូរគិតអំពីអ្នកណាដែលអាចជួយអ្នកបាននៅក្នុងការតស៊ូរបស់អ្នក។ ជោគជ័យរបស់អ្នកពឹងផ្អែកលើការគាំទ្រច្រើនប៉ុណ្ណាដែលអ្នកអាចកសាងបាននៅក្នុងសហគមន៍របស់អ្នក ជាមួយសាធារណៈជនទូទៅ និងជាក្រុមផ្សេងទៀត។

ចូរគិតអំពីអ្នកណាជាអ្នកប្រឆាំងនឹងអ្នក ។ តើគេមានចំណុចខ្លាំងនិងចំណុចខ្សោយអ្វីខ្លះ? តើគេនឹងធ្វើអ្វីខ្លះដើម្បីប្រឆាំងនឹងអ្នក? អ្នកប្រឆាំងអាចមានរួមទាំងសមាជិកសហគមន៍ផ្សេងទៀតជាច្រើន មន្ត្រីរដ្ឋាភិបាល ក្រុមហ៊ុនដែលកសាងទំនប់និងអ្នកផ្តល់ថវិកាជាដើម ។

## ៤. តើនរណាជាគោលដៅរបស់អ្នក?

ចូរអ្នកគិតអំពីនរណាដែលអាចអោយនូវអ្វីដែលអ្នកចង់បាន ។ តើនរណាគេជាអ្នកធ្វើការសំរេចចិត្តអំពីទំនប់វារីអគ្គិសនីនេះ? អ្នកនោះអាចជាមនុស្សដែលនៅក្នុងប្រទេស ឬរដ្ឋាភិបាលរបស់អ្នក ។ អ្នកនោះអាចជាក្រុមហ៊ុនដែលកសាងទំនប់នោះ ឬអាចជាអ្នកដែលផ្តល់ថវិកាសំរាប់ការសាងសង់ទំនប់ ។ អ្នកទាំងអស់នេះជាក្រុមគោលដៅរបស់អ្នក ។ តើក្រុមគោលដៅរបស់អ្នកមួយណាដែលអាចងាយនឹងមានឥទ្ធិពលទៅលើ? ប្រសិនបើ រដ្ឋាភិបាលរបស់មិនបើកទូលាយសំរាប់អ្នកនោះ អ្នកប្រហែលជាអាចនឹងងាយស្រួលជាងក្នុងការដាក់សំពាធទៅលើអ្នកផ្តល់ថវិកា ឬអ្នកកសាងទំនប់វិញ ។

## ៥. តើយុទ្ធសាស្ត្របែបណាដែលអាចផ្លាស់ប្តូរគំនិតរបស់គោលដៅអ្នក?



តើអ្វីទៅដែលអាចធ្វើអោយក្រុមគោលដៅធ្វើការផ្លាស់ប្តូរនូវគោលគំនិតរបស់គេ ហើយងាកមកគាំទ្រ នូវតំរូវការរបស់អ្នកវិញ ។ តើការតវ៉ាអាចនឹងមានប្រសិទ្ធិភាពដែរឬទេ? តើរបាយការណ៍របស់អ្នកសារព័ត៌មានអាចធ្វើអោយពួកគេផ្លាស់ប្តូរគំនិតដែរឬទេ? តើសកម្មភាពរបស់អ្នកតាមផ្លូវច្បាប់អារម្មណ៍មានប្រសិទ្ធិភាពដែរឬទេ? ជាទូទៅ ការរួមបញ្ចូលនូវសកម្មភាពជាច្រើន គឺជាជោគជ័យមួយយ៉ាងល្អ ។ ចូរអ្នកធ្វើកម្មវិធីពេលវេលាដែលរាប់បញ្ចូលទាំងសកម្មភាពរបស់អ្នកផង ។ ចូរអោយប្រាកដថាតើសមាជិករបស់អ្នកមួយណាទទួលខុសត្រូវចំពោះសកម្មភាពមួយណា ។ នេះគឺជាយុទ្ធសាស្ត្រតស៊ូមតិរបស់អ្នក ។

## ៦. តើការគបត្ថម្ភអ្វីខ្លះដែលអ្នកចាំបាច់សំរាប់យុទ្ធនាការរបស់អ្នក?

យុទ្ធនាការនីមួយៗគឺចាំបាច់ត្រូវការធនធានជាច្រើនមិនថាការរៀបចំក្បួនដង្ហែរបញ្ចេញមតិ ការប្រើប្រាស់កុំព្យូទ័រនិងការទាក់ទងតាមអ៊ីម៉ែល ទូរស័ព្ទ ឬការបោះពុម្ពឯកសារសំភារៈសំរាប់យុទ្ធនាការជាដើម។ ក្រុមអ្នកតស៊ូជាច្រើនពឹងផ្អែកទៅលើការបរិច្ចាគនានាពីសមាជិកនៅក្នុងសហគមន៍របស់ពួកគេ ។ ប្រភពជំនួយផ្សេងៗទៀតរួមបញ្ចូលទាំងមូលនិធិ ភ្នាក់ងារផ្តល់ជំនួយនានា និងប្រជាជនជាច្រើនទៀតនៅក្នុងប្រទេសរបស់អ្នក។ ប្រសិនបើអ្នកត្រូវការស្វែងរកមូលនិធីជំនួយ ចូរអ្នកព្យាយាមទាក់ទងទៅនិងអង្គការធំៗនានានៅក្នុងប្រទេសរបស់អ្នក ។ ពួកគេទាំងនោះអាចនឹងមានគំនិត និងបទពិសោធន៍ច្រើនក្នុងស្វែងរកធនធានទាំងនេះ។




*ធ្វើការពិភាក្សាគ្នាអំពីយុទ្ធសាស្ត្រនៃយុទ្ធនាការរបស់អ្នកនៅក្នុងសហគមន៏ ហើយត្រូវអោយប្រាកដថាអ្នករាល់គ្នាយល់ និងឯកភាពជាមួយនិងយុទ្ធសាស្ត្រទាំងនេះ ។*

## ■ យុទ្ធសាស្ត្រសំខាន់ៗសំរាប់ប្រឆាំងនឹងទំនប់

យុទ្ធសាស្ត្រខ្លះអាចមានប្រសិទ្ធភាពនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការកសាងទំនប់។ នៅទីនេះមានគំនិតមួយចំនួនសំរាប់សកម្មភាពផ្សេងៗដែលអ្នកអាចធ្វើនៅក្នុងយុទ្ធនាការរបស់អ្នកពីដើមដល់ចប់។




### រៀបចំ និងប្រមូលផ្តុំគ្នា

ចូរអ្នករៀបចំនិងប្រមូលផ្តុំប្រជាជនដែលរងការប៉ះពាល់និងសាធារណៈជនទូទៅដើម្បីអោយគេគាំទ្រការតស៊ូរបស់អ្នក។យុទ្ធនាការរបស់មានជោគជ័យទៅបាន គឺពឹងផ្អែកលើការបង្រួបបង្រួមប្រជាជនជាច្រើននាក់។ ជាញឹកញាប់ រដ្ឋាភិបាលនិងអ្នកកសាងទំនប់ នឹងព្យាយាមបង្កើតទំនាស់នៅក្នុងចំណោមសមាជិកសហគមន៍។ តាមរយៈការកសាងកម្លាំង និងឯកភាពរបស់សហគមន៍របស់អ្នកអោយបានឆាប់ វានឹងមានការពិបាកដល់អ្នកកសាងទំនប់ក្នុងការបំបែកបំបាក់អ្នកទាំងអស់គ្នា។

វិធីមួយទៀតដើម្បីប្រមូលផ្តុំប្រជាជន គឺអាចចាប់ដៃជាមួយអង្គការដទៃទៀតដើម្បីបង្កើតជាបណ្តាញមួយ។ចូរអ្នករកមើលក្រែងមានបណ្តាញក៏រិតជាតិមួយស្តីអំពីទំនប់នៅក្នុងប្រទេសរបស់អ្នក។ រៀបចំកិច្ចប្រជុំដើម្បីរៀបចំផែនការលើយុទ្ធសាស្ត្រនៃយុទ្ធនាការរបស់អ្នកនិងពិភាក្សារគ្នាអំពីសកម្មភាពដែលត្រូវធ្វើ។ បង្កើតសម្ព័ន្ធភាពជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ស្ថាប័នសិក្សា អ្នកសិក្សាស្រាវជ្រាវ អ្នកច្បាប់ និងអ្នកជំនាញខាងបច្ចេកទេសទាំងឡាយ។

រៀបចំការដើរក្បួនបាតុកម្ម កូដកម្ម ពហិការ និងការបិទផ្លូវ ដើម្បីទាក់ទាញការយកចិត្តទុកដាក់មកលើការតស៊ូរបស់អ្នក។ សកម្មភាពទាំងនេះ គឺមានជោគជ័យបំផុត ប្រសិនបើអ្នកចូលទៅរកស្ថាប័នផ្សេងៗដែលកំពុងធ្វើការសំរេចចិត្តអំពីទំនប់។ អ្នកអាចរៀបចំការប្រជុំសាធារណៈនៅក្នុងទីក្រុងតូចៗ និង រដ្ឋធានីជាច្រើនផ្សេងៗទៀត។

### ការចែកចាយព័ត៌មាន



បង្កើតសន្លឹកបណ្ណ (leaflet) ផូស្ទ័រ (poster) របាយការណ៍ និងសំភារៈដទៃទៀត ដើម្បីលើកស្ទួយការយល់ដឹងអំពីទំនប់ និងឥទ្ធិអាក្រក់របស់វាដែលអាចកើតមានលើសហគមន៍របស់អ្នក។ គេអាចចែកចាយសំភារៈទាំងនេះទៅអោយប្រជាជនដែលទទួលរងការប៉ះពាល់ សាធារណៈជនទូទៅ ក្រុមការពារបរិស្ថាន និងក្រុមការពារសិទ្ធិមនុស្សនៅទូទាំងប្រទេស និង

ទីភ្នាក់ងាររដ្ឋាភិបាល។ នេះជាវិធីល្អមួយដើម្បីធ្វើអោយការទាមទាររបស់អ្នកត្រូវបានគេដឹងឮជាសាធារណៈ។



**ធ្វើការជាមួយបណ្តាញផ្សព្វផ្សាយព័ត៌មាន**

ធ្វើអោយសាររបស់អ្នកទៅដល់សាធារណៈជនដោយប្រើវិទ្យុ ការសែតនិងទូរទស្សន៍។ វានឹងជួយដាក់សម្ពាធទៅលើរដ្ឋាភិបាល និងអ្នកកសាងទំនប់អោយស្តាប់ការទាមទាររបស់អ្នក។ អញ្ជើញអ្នកការសែតដែលបានសរសេរអំពីបញ្ហាស្រដៀងគ្នា នៅក្នុងអតីតកាល ហើយប្រាប់ពួកគេអំពីរឿងរបស់អ្នក។ រៀបចំការថ្លែងព័ត៌មាន។ អញ្ជើញបណ្តាញផ្សព្វផ្សាយអោយមកមើលសកម្មភាពរបស់អ្នក។ ផ្តល់ព័ត៌មានដល់អ្នកការសែតជាប្រចាំអំពីការតស៊ូរបស់អ្នក។ ស្នើអោយអង្គការមិនមែនរដ្ឋាភិបាលនានា និងក្រុមគាំទ្រអោយជួយកំណត់វិធីសាស្ត្រផ្សេងៗក្នុងការបញ្ចេញ និងផ្សព្វផ្សាយសាររបស់អ្នកអោយគេដឹង។

**បញ្ចុះបញ្ចូលរដ្ឋាភិបាលនិងអ្នកផ្តល់ថវិកា**

ជួបជាមួយអ្នកធ្វើការសំរេចចិត្តដើម្បីជំរាបពួកគេអោយដឹងអំពីកង្វល់របស់អ្នក។ បញ្ចុះបញ្ចូលមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងកំរិតមូលដ្ឋាន និងសមាជិករដ្ឋសភា ឬ សភាជាន់ខ្ពស់ (ព្រឹទ្ធសភា) អោយគាំទ្រការទាមទាររបស់អ្នក។ រៀបចំយុទ្ធនាការសរសេរសំបុត្រ និងញត្តិដើម្បីបញ្ជូនទៅអ្នកធ្វើការសំរេចចិត្តនៅក្នុងរដ្ឋាភិបាលរបស់អ្នកនិងអ្នកផ្តល់ថវិកាដល់ទំនប់។ ប្រសិនបើទំនប់ទទួលបានថវិកាពីធនាគារឯកជន ឬធនាគារអភិវឌ្ឍន៍សាធារណៈ ចូរធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលនានាអន្តរជាតិដើម្បីដាក់សំពាធលើអ្នកផ្តល់ថវិកាទាំងនេះ។

**ចាត់វិធានការតាមផ្លូវច្បាប់**

នៅពេលខ្លះ សកម្មភាពផ្លូវច្បាប់អាចប្រើប្រាស់បានដើម្បីពន្យាឬបញ្ឈប់ទំនប់ ឬដើម្បីអោយមានការសងសំណងដែលល្អជាងធម្មតាសំរាប់សហគមន៍ដែលរងការប៉ះពាល់។ រកអ្នកច្បាប់និងពិនិត្យមើលថាតើអ្នកកសាងទំនប់មានធ្វើអំពើខុសនឹងច្បាប់ណាមួយដែរឬទេ។ ក្រុមហ៊ុនច្បាប់ធំៗជាច្រើនធ្វើការដោយមិនយកកម្រៃចំពោះបុព្វហេតុល្អៗ។

**ស្នើឡើងនូវជំរើសផ្សេងទៀត**

ព្យាយាមរកអ្នកជំនាញអោយជួយអ្នក ក្នុងការស្នើជំរើសផ្សេងទៀតក្រៅពីការកសាងទំនប។ (សូមមើល *ជំពូក ៥* សំរាប់ព័ត៌មានបន្ថែម)។

## ជនជាតិប្រេស៊ីលចងក្រងគ្នាដើម្បីបញ្ឈប់ទំនប់ ភីឡា (Pilar)




នៅក្នុងឆ្នាំ ១៩៩០ ក្រុមហ៊ុនបរទេសដែលមានអំណាចជាច្រើនបានចង់កសាងទំនប់មួយនៅលើទន្លេ **ភីរ៉ាំងង៉ា** (Piranga) នៅក្នុងរដ្ឋ **មិនា ជើរ៉ាយ** (Mina Gerais) ប្រទេសប្រេស៊ីល។ ទំនប់ទឹកនោះនឹងធ្វើអោយប្រជាជនកសិករចំនួន ១៣៣ គ្រួសារ រើចេញពីផ្ទះទីលំនៅនិងបំផ្លាញជលផល។ ប្រជាជនដែលរស់នៅក្នុងតំបន់ក្រោមទំនប់រាប់ពាន់នាក់នឹងរងការប៉ះពាល់ពីការប្រែប្រួលកំពស់ទឹកនៅក្នុងទន្លេ។

អ្នកស្រុកមូលដ្ឋានជាច្រើននាក់អង្គការមិនមែនរដ្ឋាភិបាលមួយ អ្នកសិក្សាស្រាវជ្រាវជាច្រើននាក់ និងក្រុមព្រះវិហារសាសនា បានបង្កើតជាសម្ព័ន្ធមួយដើម្បីប្រឆាំងនឹងទំនប់ **ភីឡា**។ ពួកគេធ្វើការរួមគ្នាដើម្បីរកអោយឃើញនូវឥទ្ធិពលអាក្រក់ដែលទំនប់អាចនឹងកើតមានមកលើជីវិតការរស់នៅរបស់ពួកគេ។ ពួកគេបាននាំគ្នាអានការសិក្សារបស់ក្រុមហ៊ុននិងរកឃើញបញ្ហាជាច្រើន។ ពួកគេចែករំលែកព័ត៌មានទាំងនេះជាមួយមន្ត្រីរដ្ឋាភិបាលដែលព្រួយបារម្ភដូចគ្នាដែរ អំពីឥទ្ធិពលអាក្រក់របស់ទំនប់ទៅលើបរិស្ថាន។

អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកស្រាវជ្រាវជាច្រើន បានពន្យល់អំពីការសិក្សាផ្នែកបរិស្ថានទៅអោយសហគមន៍ ដើម្បីរៀបចំសំរាប់ការវេទិកាសាធារណៈស្តីអំពីទំនប់។ ពួកគេក៏បានជួយកសិករផងដែរ ដើម្បីរៀបចំទស្សនៈរបស់ពួកគេអំពីដីធ្លី ជីវភាព និងធនធានរបស់ខ្លួនជាមួយនឹងអ្វីដែលមាននៅក្នុងការសិក្សាផ្លូវការជាច្រើន។

គេបានចងក្រងសហគមន៍យ៉ាងល្អដើម្បីធ្វើវេទិកាសាធារណៈ។ កុមារជាច្រើនអានកំណាព្យអំពីទន្លេ **ភីរ៉ាំងង៉ា** ហើយអ្នកស្រុកបានជួយគ្នាលើកបដាដែលប្រាប់ដល់ក្រុមហ៊ុនថា " *Fora ថយចេញ* "។ អ្នកដឹកនាំសហគមន៍ជាច្រើននាក់ បានធ្វើសេចក្តីថ្លែងការខ្លាំងក្លាជាច្រើនដោយបញ្ចេញអោយគេដឹងអំពី

កង្វល់របស់ពួកគេ។ សំពាធមកពីអ្នកស្រុកមូលដ្ឋាន ការរិះគន់របស់ការសិក្សាស្រាវជ្រាវអំពីឥទ្ធិពលអាក្រក់របស់ក្រុមហ៊ុនទៅលើបរិស្ថាន និងកង្វល់របស់មន្ត្រីរដ្ឋាភិបាលបានបង្ខំអោយក្រុមហ៊ុនលប់ចោលគំរោងសាងសង់ទំនប់។

នៅពេលក្រុមហ៊ុនក្នុងចំណោមក្រុមហ៊ុនជាច្រើនសាកល្បងកសាងទំនប់ថ្មីមួយនៅក្នុងតំបន់ច្រើនក្រោយមក ប្រជាជនបាននិយាយម្តងទៀតថា " ទេ "។ ពួកបានចូលកាន់កាប់តំបន់ដែលក្រុមហ៊ុនធ្វើវាស់វែងដើម្បីសង់ទំនប់។ ៤៣ ថ្ងៃបន្ទាប់ អ្នកបច្ចេកទេសក្រុមហ៊ុនបានចាកចេញ។ សហគមន៍គឺបានត្រៀមខ្លួនជាស្រេចដើម្បីប្រឆាំងបើចាំបាច់។

## ការស្រាវជ្រាវរបស់អ្នកភូមិថៃ




*អស់រយៈពេលជាច្រើនឆ្នាំនាអតីតកាល ប្រជាជនដែលរស់បណ្ដោយទន្លេ សាលវិន (Salween) តាមបណ្ដោយព្រំដែនថៃនិងភូមាបានតស៊ូប្រឆាំងនឹងផែនការកសាងទំនប់របស់រដ្ឋាភិបាលរបស់ពួកគេ ។ ពួកគេបានសំរេចចិត្តថា ត្រូវធ្វើការសិក្សាស្រាវជ្រាវដោយប្រើចំណេះដឹងក្នុងមូលដ្ឋានដើម្បីចងក្រងជាឯកសារនូវរបៀបដែលពួគេនឹងប្រើប្រាស់ទន្លេ ។ អស់ពេលពីរឆ្នាំកន្លះ ប្រជាជនភាគតិចថៃអំបូរ**ការ៉ែន**ដែលមកពីភូមិចំនួន ៥០ បានប្រមូលទិន្នន័យអំពីជលផល គ្រឿងប្រដាប់នេសាទប្រពៃណី ថ្នាំបុរាណ ច្បារដំណាំនិងធនធានធម្មជាតិ ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនិងអ្នកស្ម័គ្រចិត្តបានជួយកត់ត្រានូវទិន្នន័យនិងសរសេររបាយការណ៍នានា ប៉ុន្តែសមាជិកសហគមន៏ជាច្រើន គឺជាអ្នកស្រាវជ្រាវសំខាន់ៗ ។ អ្នកភូមិបានកំណត់ឃើញថាមាន ត្រីថ្នាំបូរាណនិងរុក្ខជាតិដែលអាចបរិភោគបានជាច្រើននៅតាមដងទន្លេដែលពួកគាត់ពឹងពាក់ជាអាហារ ។ អ្នកភូមិនឹងប្រើការស្រាវជ្រាវដើម្បីបញ្ជាក់អោយឃើញជាក់ស្ដែងនូវសារៈសំខាន់គីរិតណាដែលទន្លេនិងព្រៃឈើមានចំពោះជីវិតរបស់ពួកគាត់ ។*

### វិធីសាស្ត្រធ្វើការស្រាវជ្រាវផ្ទាល់ខ្លួនរបស់អ្នក

**ជំហាន ១:** រៀបចំការប្រជុំជាមួយអ្នកគ្រប់គ្នាដែលចង់ចូលរួមក្នុងការស្រាវជ្រាវ ។ អញ្ជើញប្រជាជនពីភូមិដែលរងការប៉ះពាល់អោយបានច្រើនតាមតែអាចធ្វើបាន ។ និយាយអំពីរបៀបទាំងអស់ដែលអ្នកពឹងផ្អែកលើទន្លេដើម្បីជីវភាពរបស់អ្នក ហើយសំរេចយកអ្វីដែលអ្នកចង់ធ្វើការស្រាវជ្រាវអោយដឹង ។

**ជំហាន ២:** ចែកគ្នាទៅជាច្រើនក្រុមដើម្បីធ្វើការស្រាវជ្រាវ ។ ក្រុមត្រូវតែរួមបញ្ចូលប្រជាជនដែលចេះដឹងជំនាញនៅក្នុងវិស័យដែលយើងកំពុងស្រាវជ្រាវ ។ ឧទាហរណ៍ អ្នកនេសាទគួរធ្វើការស្រាវជ្រាវអំពីការនេសាទ ហើយអ្នកដាំដំណាំគួរធ្វើការស្រាវជ្រាវអំពីច្បារដំណាំតាមដងទន្លេ ។

**ជំហាន ៣:** សំរេចយកវិធីសាស្ត្រអ្វីដែលអ្នកត្រូវប្រើនៅក្នុងការស្រាវជ្រាវរបស់អ្នក ។ នៅទីនេះមានគំនិតខ្លះ :

*ជលផល* : ចែកស្ទឹងឬទន្លេទៅជាតំបន់តូចៗ ។ នៅក្នុងតំបន់នីមួយៗ ដើរតាមច្រាំងទន្លេ និងធ្វើការវាស់វែង។ បន្ទាប់ពីត្រីមួយៗត្រូវបានចាប់បានហើយនោះ ប្រមូលគំរូនៃពូជត្រីច្រើនប្រភេទ។ រៀបចំការប្រជុំមួយ ដើម្បីអោយប្រជាជនអាចកំណត់ស្គាល់ពូជត្រីនីមួយៗទៅតាមឈ្មោះរបស់វាដែលគេនិយមហៅនៅក្នុងមូលដ្ឋាន។ ជជែកគ្នាអំពីជំរក ផ្លូវបំលាស់ទីរបស់ពួកវា ទំហំ ទំងន់ និងរបៀបរបបពងកូនរបស់វា។ ប្រសិនបើអ្នកមានម៉ាស៊ីនថត ថតរូបពូជត្រីនីមួយៗដែលគេចាប់បាន។ ដាក់រូបថតនីមួយចូលទៅសៀវភៅមួយ ហើយសរសេរព័ត៌មានទាំងអស់អំពីត្រីនៅជាប់ខាងក្រោមរូបថត។

*ច្បារដំណាំតាមច្រាំងទន្លេ* : ចែកទន្លេទៅជាតំបន់តូចៗ។ ក្នុងតំបន់នីមួយៗ ចូរដើរតាមច្រាំងទន្លេ និងធ្វើការវាស់វែងច្បារដំណាំតាមច្រាំងទន្លេនីមួយៗ ។ កត់ឈ្មោះអ្នកដែលជាម្ចាស់ច្បារដំណាំ នីមួយៗ ដំណាំដែលមនុស្សម្នាក់ៗដាំនៅក្នុងច្បារ និងរបៀបដែលគេប្រើប្រាស់បន្លែ (ឧទាហរណ៍ សំរាប់បរិភោគ ឬ លក់ដូរ)។ ប្រសិនបើគេលក់បន្លែនៅឯផ្សារ ចូរកត់ចំនួនលុយដែលគេលក់ បាន។

**ជំហាន ៩:** កត់លទ្ធផលដែលអ្នករកឃើញទុក។ សំរេចចិត្តថាត្រូវប្រើលទ្ធផលនោះដោយរបៀបណា ដើម្បីជះឥទ្ធិពលលើអ្នកធ្វើការសំរេចចិត្តជាច្រើនរូប។

## ■ តើអ្នកអាចធ្វើអ្វីបានខ្លះនៅដំណាក់កាលនីមួយៗនៃការកសាងទំនប់?

ផ្នែកមួយនេះអធិប្បាយអំពីដំណាក់កាលបីនៃការកសាងទំនប់ទឹកនិងសកម្មភាពជាក់លាក់ដែលអ្នកអាចធ្វើបាននៅតាមដំណាក់កាលនីមួយៗ។ ដំណាក់កាលធំៗចំនួនបីនៃការកសាងទំនប់គឺ ដំណាក់កាលមុន-ការកសាង ដំណាក់កាលកសាង និងប្រតិបត្តិការរបស់ទំនប់។

### ដំណាក់កាល ១ : មុន-ការកសាងទំនប់វារីអគ្គិសនី

រយៈពេល : ២ ទៅ ២០ ឆ្នាំ ឬ យូរជាងនេះ។

**តើមានអ្វីកើតឡើងខ្លះនៅក្នុងដំណាក់កាលនេះ?**

មុននឹងគេកសាងទំនប់អ្នកកសាងទំនប់ បង្កើតផែនការផ្សេងៗ និងធ្វើអោយចប់សព្វគ្រប់នូវការសិក្សាស្រាវជ្រាវជាច្រើន ដើម្បីមើលអោយដឹងថាតើការកសាងទំនប់អាចធ្វើទៅកើតដែរឬទេ។ ពួក



*អ្នកវាស់ស្ទង់និងឧបករណ៍សំរាប់ខួង ជាធម្មតាគឺជាសញ្ញាទីមួយដែលបង្ហាញថាគេកំពុងរៀបផែនការសង់ទំនប់ក្នុងតំបន់របស់អ្នក*

គេក៏ចង់ដឹងដែរថា តើទំនប់អាចមានឥទ្ធិពលអ្វីខ្លះ ។ ការសិក្សាស្រាវជ្រាវភាគច្រើន គឺធ្វើឡើងដោយក្រុមហ៊ុនបរទេស ។

**១. ការសិក្សាស្រាវជ្រាវភាពអាចទៅរួច-មុនការសាងសង់**

ការសិក្សាធ្វើអោយប្រាកដថាគេអាចសង់ទំនប់និងប្រតិបត្តិការមុខងារទំនប់បាន ។ វាកំណត់ថា តើតំបន់នោះសមស្របសំរាប់កសាងទំនប់ឬទេ ធ្វើការប៉ាន់ប្រមាណថាគេអាចផលិតថាមពល និងទឹកបានប៉ុន្មាន ហើយប៉ាន់ប្រមាណចំនួនប្រាក់ដែលត្រូវចំណាយលើការសាងសង់ទំនប់ ។

**២. ការសិក្សាពីភាពអាចទៅរួចនិងការរៀបបែបផែនលំអិត**

ការសិក្សានេះពិនិត្យមើលលើព័ត៌មានចាំបាច់ដែលត្រូវការដើម្បីកសាងទំនប់ ដូចជាធាតុអាកាស ភូគព្ភសាស្ត្រ មានបរិមាណទឹកប៉ុន្មាននៅក្នុងទន្លេឬស្ទឹង ។ល។ ប្រសិនបើអ្នកឃើញមានជនប្លែកមុខនៅក្នុងតំបន់ ហើយកំពុងធ្វើការវាស់វែងនិងខួងដីនោះ អញ្ចឹងពួកគេទំនងជាកំពុងធ្វើការសិក្សាពីលទ្ធភាពដែលអាចទៅរួច នោះហើយ ។

៣. **ការសិក្សាវាយតំលៃទៅលើហេតុប៉ះពាល់លើបរិស្ថាន** (EIA): EIA គឺត្រូវពិនិត្យមើលឥទ្ធិពលរបស់ទំនប់ទៅលើបរិស្ថាន ។ វាក៏ត្រូវផ្តល់យោបល់អំពីវិធានការ **កាត់បន្ថយផលប៉ះពាល់** សំរាប់បញ្ហាបរិស្ថានដែលទំនប់នឹងបង្កើតឡើង ។ EIA ជាធម្មតានិយាយថា ផលប៉ះពាល់ភាគច្រើនអាចនឹងកាត់បន្ថយបាន ហើយគេគួរកសាងទំនប់ ។

៤. **ផែនការតាំងទីលំនៅសារជាថ្មី ឬផែនការអភិវឌ្ឍន៍សង្គម :** វារួមបញ្ចូលទាំងផែនការផ្តល់ទីលំនៅថ្មីដល់ប្រជាជនដែលរស់នៅក្នុងតំបន់អាងស្តុកទឹក ។ វាក៏បញ្ចូលផងដែរនូវផែនការសំរាប់អោយមានការសងសំណងដល់ប្រជាជនដែលទទួលរងការប៉ះពាល់ ។ ប្រជាជនដែលទទួលរងការប៉ះពាល់ដែលរស់នៅក្នុងតំបន់ក្រោមទំនប់ ជាញឹកញាប់ត្រូវបានដាក់នៅក្រៅផែនការនេះ ។

កាលណាគេធ្វើការសិក្សាទាំងនេះរួចរាល់ហើយ អ្នកកសាងទំនប់ជួបជាមួយរដ្ឋាភិបាលនិងធនាគារដើម្បីរកថវិការសំរាប់ការកសាងទំនប់ ។

## តើអ្នកអាចធ្វើអ្វីបានខ្លះនៅចំណាក់កាលនេះ?

ពេលនេះគឺជាពេលល្អបំផុតសំរាប់ដាក់ឥទ្ធិពលលើគំរោងសាងសង់ទំនប់ ។ ប្រសិនបើអ្នកគិតថាទំនប់នឹងធ្វើអោយរងទុក្ខដល់សហគមន៏របស់អ្នកនោះ អញ្ចឹងត្រូវព្យាយាមបញ្ឈប់ទំនប់នោះ។ ចូររៀនសូត្រអំពីសិទ្ធិបែបណាខ្លះដែលអ្នកមាននៅក្រោមច្បាប់ក្នុងស្រុករបស់អ្នក។ ទាមទារអោយរដ្ឋាភិបាលរៀបចំវេទិការសាធារណៈ ដើម្បីអោយអ្នកអាចជជែកអំពីអ្នកណាជាអ្នកទទួលផលចំណេញនិងអ្នកណាជាអ្នកខូចខាតដោយសារទំនប់។ ព្យាយាមចាត់វិធានការផ្លូវច្បាប់ដើម្បីបញ្ឈប់ទំនប់។ ធ្វើការជាមួយអ្នកជំនាញដើម្បីបង្កើតជំរើសផ្សេងដែលល្អជាងទំនប់ ឬ ផែនការសងសំណងនិង ធ្វើអោយសាធារណៈជនដឹងលឺពីរឿងនេះ។

ទោះបីជាយុទ្ធនាការបញ្ឈប់ទំនប់របស់អ្នកទទួលបានជោគជ័យក៏ដោយ រដ្ឋាភិបាលអាចនឹងសាកល្បងសង់ទំនប់ជាថ្មីម្តងទៀត។ កសាងសម្ព័ន្ធមួយដែលមានសមត្ថភាពខ្លាំងក្លា គឺជាកត្តាសំខាន់សំរាប់ការតស៊ូវែងឆ្ងាយរបស់អ្នក។

## ពិនិត្យការសិក្សារបស់ទំនប់ឡើងវិញ

ទាមទារអោយគេបង្ហាញការសិក្សារបស់គេដល់សាធារណៈជន។ ប្រសិនបើអ្នកអាចយកច្បាប់ចម្លងរបស់ការសិក្សានោះបាន ចូររកអ្នកជំនាញអោយពិនិត្យវាឡើងវិញ ហើយបោះពុម្ភវាឡើងវិញក្រោយពីមានការពិនិត្យហើយ។ អ្នកជំនាញជាច្រើននឹងធ្វើការពិនិត្យនេះដោយមិនយកលុយ។ ការពិនិត្យរបស់អ្នកជំនាញអាចកំណត់ឃើញបញ្ហាជាច្រើនជាមួយការសិក្សានោះ ហើយព្យាករណ៏ទុកនូវអ្វីដែលអាចកើតជាបញ្ហាប្រសិនបើគេកសាងទំនប់រួច។

## ធ្វើការសិក្សារបស់អ្នកផ្ទាល់

ជាញឹកញាប់ គេសង់ទំនប់ដោយមិនបានធ្វើការសិក្សាផ្សេងៗ ដែលបង្ហាយអោយឃើញថា ប្រជាជនគឺពឹងផ្អែកលើទន្លេឬស្ទឹងទេ។ ប្រសិនបើគេងសាងសង់ទំនប់ ប្រជាជនមិនទំនងជាបានទទួលការសងសំណងពេញលេញឡើយ ព្រោះមិនមានព័ត៌មានអំពីអ្វីដែលគេត្រូវបាត់បង់។ រឿងសំខាន់ គឺត្រូវកត់ទុកនូវរបៀបដែលសហគមន៏របស់អ្នកពឹងផ្អែកលើទន្លេឬស្ទឹង។ អង្កេតមូលដ្ឋាននេះ អាចបង្ហាញអោយឃើញផងដែរនូវការខូចខាតដែលអាចកើតមានឡើង។ អ្នកភូមិជនជាតិថៃ បានបង្កើតវិធីស្រាវជ្រាវមួយសំរាប់ធ្វើកិច្ចការនេះដែលគេហៅថា " ការស្រាវជ្រាវរបស់អ្នកភូមិថៃ " ។ (សូមមើលប្រអប់នៅលើទំព័រ ២៣) ។

## ចូលទៅរកអ្នកផ្តល់ថវិកា

រកអោយឃើញថាអ្នកណាទំនងជាផ្តល់ថវិកាដល់ទំនប់ប្រសិនបើអ្នកផ្តល់ថវិកាគឺមកពីប្រទេសក្រៅ ត្រូវទាក់ទងអង្គការនានានៅក្នុងប្រទេសទាំងនោះ ដើម្បីស្នើអោយគេជួយគាំទ្រយុទ្ធនាការរបស់អ្នក។ សូមមើលបញ្ជីទំនាក់ទំនងនៅចុងបញ្ចប់នៃគោលការណ៏ណែនាំនេះ។

### ទាមទារអោយមានកិច្ចព្រមព្រៀងផ្លូវច្បាប់

ប្រសិនបើអ្នកសំរេចចិត្តរើចេញ ចូរធ្វើអោយប្រាកដថា មានកិច្ចព្រមព្រៀងផ្លូវច្បាប់មួយដែលមានចែងពីអ្វីៗគ្រប់យ៉ាង ដែលបានសន្យាចំពោះអ្នក។ សូមកុំចុះហត្ថលេខាលើអ្វីដែលអ្នកយល់មិនច្បាស់លាស់។ រដ្ឋាភិបាល និងអ្នកកសាងទំនប់ជាច្រើន ជាញឹកញាប់នឹងប្រាប់អ្នកថា អ្នកនឹងទទួលបានផ្ទះថ្មីនិងដីដែលល្អជាងមុន ប៉ុន្តែរឿងនេះមិនងាយក្លាយជាការពិតទេ។




*កុំចុះហត្ថលេខាលើអ្វីដែលអ្នកយល់មិនច្បាស់លាស់!*

## ដំណាក់កាល ២ : ការកសាង

រយៈពេល : ៥ ទៅ ១៥ ឆ្នាំ ។ ការកសាង ជាញឹកញាប់ប្រើពេលយូរជាងរយៈពេលដែលបានគិតទុក។ ពេលខ្លះគឺមកពីការលំបាកខាងបច្ចេកទេស និងពេលខ្លះទៀត គឺមកពីអំពើពុករលួយ។

### មានអ្វីកើតឡើងនៅចំណាក់កាលនេះ?

ដំណើរការកសាងសំរាប់ទំនប់ជាធម្មតាគឺដូចនេះ :



### តើអ្នកអាចធ្វើអ្វីបាននៅដំណាក់កាលនេះ

យុទ្ធនាការរបស់អ្នកនៅតែអាចមានជោគជ័យដដែល ទោះបីជាការសាងសង់ទំនប់បានចាប់ផ្ដើមហើយក៏ដោយ។ អ្នកអាចនឹងបញ្ឈប់ការសាងសង់ ទទួលបានសំណងល្អជាងធម្មតា ឬ ធ្វើអោយគំរោងមានលក្ខណៈប្រសើរឡើង។ រឿងសំខាន់ដែលត្រូវធ្វើ គឺត្រូវបន្តការតស៊ូរបស់អ្នកតទៅទៀត។

### រៀបចំបាតុកម្មរបស់អ្នក

នៅដំណាក់កាលនេះ ក្រុមខ្លះព្យាយាមបញ្ឈប់ការសាងសង់មិនអោយកើតឡើង ដោយការរៀបចំការបិទផ្លូវចេញចូល និងទ្រង់ទ្រាយផ្សេងទៀតនៃ **សកម្មភាពផ្ទាល់មិនហឹង្សា** ។ ប្រសិនបើអ្នកមិនអាចធ្វើដូចនេះបានទេនោះ ចូរតាមឃ្លាំមើលការសាងសង់និងការតាំងទីលំនៅសារជាថ្មី។ ប្រសិនបើអ្នកកសាងទំនប់ ឬ រដ្ឋាភិបាលមិនព្រមធ្វើតាមអ្វីដែលពួកគេបាននិយាយថា គេនឹងធ្វើទេនោះ ត្រូវចងក្រងអ្នកតវ៉ានិងសកម្មភាពផ្សេងទៀតដើម្បីទាមទារអោយពួកគេធ្វើតាមពាក្យសន្យា។

### ធ្វើការជាមួយអង្គការអន្តរជាតិនានា

ប្រសិនបើទំនប់ទទួលថវិកាពីធនាគារអភិវឌ្ឍន៍ទូទៅ ចូរធ្វើការជាមួយអង្គការអន្តរជាតិដើម្បីធ្វើអោយច្បាស់លាស់ថា អ្នកផ្ដល់លុយបានទទួលព័ត៌មានអំពីបញ្ហាផ្សេងៗដែលកើតជាមួយនឹងទំនប់។ ពេលខ្លះអ្នកផ្ដល់ថវិកានេះ អាចដាក់សំពាធលើអ្នកកសាងទំនប់ ប្រសិនបើពួកគេកំពុងសាងសង់ឬអនុវត្តការតាំងទីលំនៅសារជាថ្មីក្នុងលក្ខណៈមិនល្អនោះ។ ប្រសិ ... អ្នកផ្ដល់លុយនឹងបញ្ឈប់ការទម្លាក់លុយអោយរហូតដល់អ្វីៗបានប្រសើរ ...

ស្ដារស្ថានភាពទន្លេឡើងវិញ

## ដំណាក់កាលទី ៣ : ប្រតិបត្តិការមុខងារទំនប់

រយៈពេល : ប្រហែល ៥០ ឆ្នាំ (ពេលខ្លះច្រើន ពេលខ្លះតិចជាង)។




### អ្វីកើតឡើងនៅក្នុងដំណាក់កាលនេះ?

ក្រោយពីទំនប់ជាច្រើន ត្រូវបានសាងសង់រួចរាល់ហើយនោះ ពួកវាចាប់ផ្ដើមមានដំណើរការ។ អាងស្តុកទឹកខ្លះពេញទៅដោយល្បាប់ និងកករយ៉ាងលឿន។ ទំនប់ខ្លះអាចក្លាយទៅជាគ្មានសុវត្ថិភាព ឬថែមទាំងបាក់បែកទៀតផង។

កាលណាទំនប់មួយ បានឈានដល់ចុងបញ្ចប់នៃអាយុកាលរបស់វាហើយនោះ គេត្រូវជួសជុលវា ឬ បំផ្លាញចោល។

ក្រុមអ្នកតស៊ូជាច្រើនជុំវិញពិភពលោកគឺកំពុងទាមទារថាត្រូវបំផ្លាញទំនប់ចោល ពីព្រោះវាមានឥទ្ធិពលមិនល្អមកលើប្រជាជន។

**តើអ្នកអាចធ្វើអ្វីបាននៅចំណោក់កាលនេះ?**

**ទាមទារអោយមានការសងសំណង**

ទោះបីទំនប់ត្រូវបានសាងសង់ឡើងក៏ដោយ ក្រុមហ៊ុននិងរដ្ឋាភិបាលជាច្រើន អាចនៅតែមានកាតព្វកិច្ចស្របតាមផ្លូវច្បាប់ដែលត្រូវផ្តល់សំណង។ អ្នកគួរតែធ្វើការស្រាវជ្រាវចំណុចនេះថាតើសំណងនេះអាចអនុវត្តបានចំពោះ អ្នកដែរឬទេ។

ប្រជាជនជាច្រើននាក់ជុំវិញពិភពលោក ដែលអ្នកទទួលរងការប៉ះពាល់ពីទំនប់ជាច្រើននោះ គឺកំពុងធ្វើការទាមទារ **សំណង** ឬ ការសងជំងឺចិត្តចំពោះការខូចខាតកន្លងមក។ ពួកគេគឺកំពុងទាមទារថា ទីភ្នាក់ងារដែលបានកសាងទំនប់ (រដ្ឋាភិបាល ធនាគារ និង ក្រុមហ៊ុន) ត្រូវទទួលខុសត្រូវលើផលប៉ះពាល់ផ្សេងៗរបស់ទំនប់ និងបង់លុយសងជំងឺចិត្តទៅអោយសហគមន៍ដែលទទួលរងការប៉ះពាល់។ ខ្លះបានទទួលជោគជ័យ។ (សូមមើលប្រអប់នៅលើទំព័របន្ទាប់)។

**ការទាមទារប្រែប្រួលក្នុងប្រតិបត្តការមុខងារទំនប់**

អ្នកអាចទាមទារផងដែរអោយមានការប្រែប្រួលនៅក្នុងប្រតិបត្តិការមុខងាររបស់ទំនប់ ដើម្បីជួយអោយទន្លេ ឬ ស្ទឹងហូរតាមធម្មជាតិកាន់តែខ្លាំងឡើង។ ការធ្វើរបៀបនេះ គេហៅថា **រៀបចំ-ប្រតិបត្តិការសារជាថ្មី** ។ ប្រការនេះអាចពាក់ព័ន្ធនឹងការកែប្រែបរិមាណអគ្គីសនីដែលផលិតចេញមកទៅតាមពេលវេលាខុសគ្នាៗក្នុងមួយថ្ងៃ ឬ វាអាចមានន័យម្យ៉ាងទៀតថា បញ្ចេញទឹកច្រើនថែមទៀតទៅតំបន់ក្រោមទំនប់។ ក្រុមអ្នកតស៊ូជាច្រើននៅជុំវិញពិភពលោកគឺកំពុងប្រឆាំងនឹងទំនប់ដើម្បីអោយគេកែប្រែប្រតិបត្តិការមុខងារវាឡើងវិញ។

# **ការទាមទារសំណងនៅក្នុងប្រទេសហ្គាតេម៉ាឡា**




ក្នុងពេលដែលប្រទេស **ហ្គាតេម៉ាឡា** កំពុងស្ថិតក្នុងកណ្តាលសង្គ្រាមស៊ីវិលនោះ រដ្ឋាភិបាលបានកសាងទំនប់ **ជីស៊យ** (Chi Xoy) នៅលើទឹកដី **ម៉ាយ៉ា អាជី** (Maya Achi) ។ **ម៉ាយ៉ា អាជី** គឺជាអំបូរជនជាតិដើម ។ ក្រោយពីមានប្រជាជនមួយចំនួនបដិសេធមិនព្រម រើចេញដើម្បីទុកអោយកសាងទំនប់នោះ ជាដំបូងកងកម្លាំងបានសម្លាប់មនុស្សអស់ប្រហែល ៤០០ នាក់នៅក្នុងឆ្នាំ ១៩៨២។ ប្រជាជនច្រើនជាង ៣៥០០ នាក់ត្រូវបានបង្ខំអោយចាកចេញពីទឹកដីរបស់ពួកគេ។ មនុស្សជាច្រើនពាន់នាក់ទៀតបានបាត់បង់ដីធ្លីនិងជីវភាពរបស់ពួកគេ។

អស់ពេលជាច្រើនឆ្នាំ អ្នកដែលនៅរស់បានរស់នៅក្នុងភាពក្រីក្រហួសនិស្ស័យ។ ប៉ុន្តែពួកគេមិនដែលលះបង់ការទាមទាររកយុត្តិធម៌របស់ពួកគេឡើយ។ ប្រជាជនដែលទទួលរងការប៉ះពាល់ ឥឡូវនេះកំពុងទាមទារសំណងសំរាប់ការខូចខាតខាងសង្គម ផ្លូវកាយ និង សេដ្ឋកិច្ចរបស់ពួកគេ។

សហគមន៍ដែលទទួលរងការប៉ះពាល់ រួមគ្នាជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកស្រាវជ្រាវ បានបង្កើតការសិក្សាមួយដែលចងក្រងអំពីផលប៉ះពាល់អាក្រក់ទាំងឡាយរបស់ទំនប់មកលើបរិស្ថាន ធនធានធម្មជាតិ ភាពក្រីក្រ និងធនធានដែលផ្គត់ផ្គង់សំរាប់អាហារចិញ្ចឹមជីវិត។ ការសិក្សានេះបានជួយបង្ហាញនូវអ្វីដែលជនជាតិ **ម៉ាយ៉ា អាជី** បាត់បង់និងហេតុអ្វីបានជាពួកគេសមទទួលបានសំណងទាំងនេះ។

ក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៤ សហគមន៍ជាច្រើនបានរៀបចំការតវ៉ាធំមួយនៅឯតំបន់ទំនប់។ ក្រោយពីបានកាន់កាប់ទំនប់អស់ពេលពីរថ្ងៃមក រដ្ឋាភិបាលយល់ព្រមបង្កើតគណៈកម្មការមួយដើម្បីចរចារអោយមានការសងសំណង។ គណៈកម្មការបានប្រារព្ធកិច្ចប្រជុំលើកដំបូងស្តីពីទំនប់នេះនៅក្នុងខែធ្នូ ឆ្នាំ ២០០៥។

**គ្រីស្តូបាល អូស្វ៊ូរីអូ** មនុស្សម្នាក់នៅក្នុងចំណោមអ្នករួចផុតពីការសម្លាប់បាននិយាយថា " សំណងធ្វើអោយយើងស្តារឡើងវិញនូវភាពថ្លៃថ្នូររបស់យើង និងគោរពចំពោះវប្បធម៌និងសិទ្ធិរបស់យើង ។ ការសងសំណងមានន័យថា សំណងនឹងជួយអោយប្រជាជនយើងនឹងអាចផ្តល់អោយគ្រួសារ និងជីវិតយើងនូវភាពសុខសប្បាយឡើងវិញ ដើម្បីបង្កើតគំរោងដែលផ្តល់គុណប្រយោជន៍ដល់សហគមន៍ និងបង្កើនសមត្ថភាពរបស់ប្រជាជន។ សំណងមានអារម្មណ៍ថាមានអនាគត និងមានអារម្មណ៍ល្អចំពោះជីវិត។

## សំណួរសំរាប់ពិភាក្សា


-ប្រសិនបើអ្នកទទួលរងការប៉ះពាល់ពីទំនប់
តើអ្វីខ្លះដែលអ្នកបានបាត់បង់ចាប់តាំងពីពេល
ដែលទំនប់ត្រូវបានសាងឡើង?
-តើសំណងបែបណាដែលអាចជួយជួសជុស
ដល់ការខូចខាតដែលបានកើតឡើងចំពោះ
សហគមន៏របស់អ្នក?
-តាមអ្នកគិត តើអ្នកណាជាអ្នកសងសំណង
អោយអ្នក? រដ្ឋាភិបាល ? អ្នកផ្តល់ថវិកាសំរាប់
សាសង់ទំនប់?
- តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីដាក់សំពាធលើ
អ្នកទាំងឡាយណា ដែលទទួលខុសត្រូវលើការ
សងសំណងទាំងនេះ?

# ជំពូក ៥

# ជំរើសផ្សេងទៀត ដែលមិនមែនជាទំនប់វារីអគ្គិសនីធំៗ

មានជំរើសល្អៗជាងទំនប់ក្នុងការផ្តល់ទឹក ថាមពល និងការការពារទឹកជំនន់ជូនដល់ប្រជាជន។ ជំរើសទាំងនេះជាធម្មតាគឺអស់លុយតិច កសាងលឿនជាង និងមិនបង្កទុក្ខភ័យដល់ប្រជាជននិងបរិស្ថានជាងទំនប់ធំៗ។

នៅជុំវិញពិភពលោក សហគមន៏ដែលរងការប៉ះពាល់ពីទំនប់វារីអគ្គិសនីនិងអង្គការក្រៅរដ្ឋាភិបាលបានប្រមូលព័ត៌មានអំពីជំរើសផ្សេងទៀតក្រៅពីទំនប់ធំៗ ។ ពួកគេបានប្រើប្រាស់ព័ត៌មានទាំងនេះដើម្បីដាក់សំពាធលើរដ្ឋាភិបាលរបស់ពួកគេដើម្បីអោយមានការគាំទ្រប្រសើរឡើងចំពោះជំរើសផ្សេងទៀត ដែលជាសក្តានុពល។ ការខិតខំប្រឹងប្រែងរបស់ពួកគេបានជួយបញ្ឈប់ការសាងសង់ទំនប់ដែលមានលក្ខណៈបំផ្លាញនិងមិនចាំបាច់។

នៅក្នុងជំពូកនេះ យើងពិភាក្សាអំពីជំរើសសក្តានុពលមួយចំនួន ដែលអាចជំនួសទំនប់ធំៗបាន និងបង្ហាញអោយឃើញនូវសកម្មភាពជោគជ័យដែលសហគមន៏ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនបានធ្វើឡើងដើម្បីគាំទ្រជំរើសសក្តានុពលដែលល្អជាង។ យើងសង្ឃឹមថា ជំពូកនេះផ្តល់ដល់អ្នកនូវគំនិតជាច្រើនអំពីជំរើសសក្តានុពលដែលអ្នកអាចជំរុញអោយមានការអនុវត្តនៅក្នុងយុទ្ធនាការរបស់អ្នក ពីព្រោះតាមតំបន់នីមួយៗមានតម្រូវការខុសៗគ្នា ហើយអ្នកនឹងត្រូវគិតរកជំរើសល្អបំផុតសំរាប់តំបន់របស់អ្នក ។

## ■ ជំរើសសក្តានុពលសំរាប់ថាមពល

មានវិធីច្រើនណាស់ ដែលរដ្ឋាភិបាលអាចផ្តល់ថាមពលដល់ប្រជាពលរដ្ឋរបស់ខ្លួនបាន។ វាគឺរួមទាំងការកាត់បន្ថយតម្រូវការថាមពល កែលំអរោងចក្រថាមពលដែលមានស្រាប់ជាច្រើនកន្លែង និងខ្សែចម្លងចរន្ត និងកសាងប្រភពថាមពលថ្មី។



*អំពូលភ្លើងដែលកាត់បន្ថយការប្រើប្រាស់ថាមពល*

### កាត់បន្ថយតម្រូវការ

រដ្ឋាភិបាលជាច្រើន អាចកាត់បន្ថយតម្រូវថាមពលដោយការលើកទឹកចិត្តដល់រោងចក្រជំនួញ និងប្រជាជនដែលរស់នៅក្នុងទីក្រុងជាច្រើនអោយប្រើថាមពលដោយប្រុងប្រយ័ត្នខ្លាំងឡើង។ ការធ្វើបែបនេះគឺអាចអស់លុយតិចនិងមានលក្ខណៈល្អប្រសើរចំពោះបរិស្ថានជាងការកសាងរោងចក្រថាមពលនិងទំនប់ថ្មី។

ល្បិចខ្លះក្នុងការសន្សំថាមពល គឺមានរួមទាំងការជួយប្រជាជនរកលុយចំណាយទិញម៉ាស៊ីននិងអំពូលភ្លើងដែលប្រើអគ្គីសនីតិច។ រដ្ឋាភិបាលជាច្រើនអាចធ្វើអោយក្រុមហ៊ុននិងប្រជាពលរដ្ឋដែលប្រើម៉ាស៊ីនដែលតំរូវការអគ្គីសនីច្រើនអោយបង់ពន្ធកាន់តែច្រើនដែរ។

រដ្ឋាភិបាលអាចជំរុញប្រជាជននិងរោងចក្រអោយប្រើផងដែរនូវអគ្គិសនីក្នុងពេលផ្សេងៗគ្នាក្នុងមួយថ្ងៃ ។ ធ្វើដូច្នេះ វាធ្វើអោយគេត្រូវសង់រោងចក្រថាមពលនិងទំនប់តិចតួចប៉ុណ្ណោះ ។

## កែលំអទំនប់វារីអគ្គិសនីដែលមានស្រាប់និងខ្សែចម្លងចរន្ត



ខ្សែចម្លងចរន្តជាច្រើន នាំយកថាមពលពីរោងចក្រថាមពលទៅដល់ប្រជាជនទីក្រុង និងរោងចក្រជាច្រើន ។ នៅក្នុងប្រទេសជាច្រើន ខ្សែចម្លងចរន្តដែលមានគុណភាពអន់អាចខ្ជះខ្ជាយថាមពលយ៉ាងច្រើន ។ ជាញឹកញាប់ គេអាចសន្សំថាមពលបានដោយការជួសជុសខ្សែចម្លងថាមពល ។

ទំនប់ដែលមានស្រាប់ឬរោងចក្រថាមពលជាច្រើន ក៏អាចត្រូវបានធ្វើការកែលំអផងដែរ ។ ដោយការសំអាតរោងចក្របារល្បាប់ចេញ និងធ្វើការកែលំអបច្ចេកទេសផ្សេងទៀត រោងចក្រថាមពលជាច្រើនអាចផលិតអគ្គិសនីច្រើនថែមទៀត ។ ការកែលំអទាំងនេះអាចអស់តម្លៃតិចនិងប្រើពេលវេលាតិចជាងការសាងសង់រោងចក្រថាមពលថ្មី ។

## កសាងប្រភពថាមពលដែលល្អជាង

នៅទីនេះមានវិធីមួយចំនួនដើម្បីផលិតថាមពលដែលបណ្តាលអោយមានការខូចខាតដល់បរិស្ថាននិងសហគមន៏តិចតួចជាងទំនប់ធំៗ ។ ភាគច្រើននៃជំរើសទាំងនេះ អាចយកទៅប្រើដើម្បីផ្តល់ថាមពលដល់ទីក្រុងនិងរោងចក្រធំៗ ឬ ផ្តល់ទៅអោយភូមិតាមជនបទជាច្រើន ។

### វារីអគ្គីសនីខ្នាតតូច



ទំនប់វារីអគ្គីសនីតូចៗជាច្រើន ជាធម្មតាគឺមានកំពស់តែពីរ បី ម៉ែត្រប៉ុណ្ណោះ ។ គេអាចកសាងពួកវាពីដី ថ្ម ឬឈើ ។ ទំនប់តូចៗ ជាញឹកញាប់មិនមានអាងស្តុកទឹកទេ ដូច្នេះជាធម្មតាពួកវាមិនធ្វើអោយប្រជាជនត្រូវរើចេញពីលំនៅដ្ឋានទេ ។ ចរន្តទឹកហូរនៅក្នុងទន្លេក៏មិនមានការប្រែប្រួលច្រើនដែរ ។ គំរោងវារីអគ្គីសនីខ្នាតតូចមែនទែន គឺមិនមានការពាក់ព័ន្ធនឹងការកសាងទំនប់ទេ ។ ពួកគេបង្វែរយកទឹកមួយចំនួនពីទន្លេឬស្ទឹងដើម្បីបង្កើតជាថាមពលឡើង ។

គំរោងវារីអគ្គីសនីខ្នាតតូចជាច្រើន អាចត្រូវបានបង្កើតឡើងនិងគ្រប់គ្រងដោយអ្នកភូមិ ។ នៅក្នុងប្រទេសចិន ឥណ្ឌា និង នេប៉ាល់ មានគំរោងវារីអគ្គីសនីខ្នាតតូចរាប់ពាន់ផ្គត់ផ្គង់ថាមពលដល់ភូមិនិងក្រុងជាច្រើន ។



## ថាមពលជីវសាស្ត្រ

នៅក្នុងប្រទេសជាច្រើន **បាយអូម៉ាស់** ( **ជីវឧស្ម័ន**) គឺជាប្រភពថាមពលយ៉ាងសាមញ្ញមែនទែនមួយ ។ បាយអូម៉ាស់នេះ គឺរួមបញ្ចូលនូវរាល់កាកសំណល់ ដែលបានមកពីរុក្ខជាតិនិងសត្វ ។ កាកសំណល់របស់សត្វនិងកសិកម្មត្រូវបានយកទៅប្រើប្រាស់ ដើម្បីដុតកំដៅចង្ក្រានទៅបង្កើតជាឧស្ម័ននិងដុតកំដៅអាគារ ។

គេអាចប្រើបាយអូម៉ាស់ផងដែរក្នុងទំហំធំ ។ នៅក្នុងប្រទេសជាច្រើនដែលគេផលិតអំពៅក្រុមហ៊ុនជាច្រើនបានចាប់ផ្តើមដុតកាកអំពៅ ដើម្បីបង្កើតអគ្គីសនី ។ អង្កាមនិងកាកសំណល់ឈើក៏អាចយកទៅប្រើបានដែរ ។



## ថាមពលព្រះអាទិត្យ

គេអាចដាក់បន្ទះសូឡា (solar) នៅលើដំបូលផ្ទះដើម្បីទាញយកថាមពលពីព្រះអាទិត្យហើយប្រើវាសំរាប់ដុតកំដៅទឹក ឬផលិតជាថាមពល ។ បន្ទះធំៗ ប្រមូលបានកំដៅព្រះអាទិត្យច្រើន និងផលិតបានថាមពលច្រើនដែរ ។



## ថាមពលខ្យល់ ( វាយោថាមពល)

ថាមពលខ្យល់គឺបង្កទុក្ខទោសដល់បរិស្ថានតិចជាងទំនប់ធំៗ ។ នៅក្នុងប្រទេសអឺរ៉ុបជាច្រើន ដូចជាអាល្លឺម៉ង់ និង អេស្ប៉ាញ មានថាមពលជាច្រើនត្រូវបានផលិតដោយតួរប៊ីនវិលដោយកម្លាំងខ្យល់ ។ ប្រទេសជាច្រើនដូចជា ឥណ្ឌា ចិន អាហ្វ្រិកខាងត្បូង និងប្រេស៊ីល ឥឡូវនេះគឺកំពុងកសាងតួប៊ីនដើរដោយកម្លាំង ខ្យល់ជាច្រើនកន្លែងដើម្បីបង្កើតថាមពលស្អាត ។

**ថាមពលកំដៅផែនដី**

ថាមពលកំដៅផែនដីប្រើប្រាស់កំដៅដែលចេញពីខាងក្នុងផែនដី ដើម្បីផលិតថាមពល។ កំដៅនេះធ្វើអោយអាងទឹកនៅក្នុងផែនដីឡើងក្តៅហើយកើតចេញជាចំហាយ។ គេអាចខួងអណ្តូងដើម្បីនាំយកទឹកកំដៅផែនដីដែលក្តៅមកកាន់ផ្ទៃផែនដីខាងលើ។ បន្ទាប់មកគេអាចប្រើប្រាស់វត្ថុរាវនេះដើម្បីបង្កើតអគ្គិសនីនៅឯរោងចក្រថាមពល។ ប្រទេសហ្វីលីពីន និងអែលសាវ៉ាឌ័រ បង្កើតបានអគ្គិសនី ២៥% នៃអគ្គិសនីទាំងអស់មកពីប្រភពកំដៅផែនដី។

**អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនរកឃើញជំរើសផ្សេងទៀតដែលល្អជាងនៅក្នុងប្រទេសអ៊ូហ្កាន់ដា**




រដ្ឋាភិបាល **អ៊ូហ្កាន់ដា** និងធនាគារពិភពលោកបាននិយាយយូរមក ហើយថាគេត្រូវការទំនប់ **ប៊ូចាហ្កាលី** (Bujagali) ដើម្បីឆ្លើយតបទៅនឹងតម្រូវការថាមពលរបស់ប្រទេស **អ៊ូហ្កាន់ដា**។ ប៉ុន្តែអង្គការនានា (NGOs) នៅក្នុងប្រទេស **អ៊ូហ្កាន់ដា** ចង់រកជំរើសផ្សេងទៀតដែលមិនសូវមានការខូចខាតដល់បរិស្ថាន និងមានលក្ខណៈប្រសើរចំពោះប្រជាជន។ ដូច្នេះពួកគេបានចាប់ផ្តើមស៊ើបអង្កេតជំរើសផ្សេងទៀតដែលមានខ្នាតធំៗ។

ក្នុងខែមេសា ឆ្នាំ ២០០៣ សមាគមន៍ជាតិនៃអង្គការមិនមែនរដ្ឋាភិបាល **អ៊ូហ្កាន់ដា** បានរៀបចំសន្និសិទ្ធធំមួយអំពីថាមពលកំដៅផែនដី។ ជំរើសផ្សេងនេះគិតពិចារណាអំពីការសន្យាល្អបំផុតដល់ប្រទេស **អ៊ូហ្កាន់ដា**។ អ្នកជំនាញខាងកំដៅផែនដីមកពីជុំវិញពិភពលោក មន្ត្រីរដ្ឋាភិបាល ក្រុមបរិស្ថានជាច្រើន និងសាធារណៈជនទូទៅបានចូលរួមក្នុងអង្គប្រជុំនេះ។

បន្ទាប់ពីមហាសន្និបាទ ក្រសួងថាមពលរបស់ប្រទេស **អ៊ូហ្កាន់ដា** បានបង្កើតក្រុមមួយដើម្បីសិក្សាអំពីជំរើសផ្សេងទៀតជាច្រើនសំរាប់ផលិតថាមពលជូនប្រទេស។ សូមអរគុណចំពោះការខំប្រឹងប្រែងរបស់ NAPE ។ គេលែងមើលឃើញវារីអគ្គិសនីថា ជាជំរើសថាមពលតែមួយរបស់ប្រទេស **អ៊ូហ្កាន់ដា** ទៀតហើយ។ ជំរើសដែលល្អជាង ថោកជាង និង ស្អាតជាង ដូចជាថាមពលកំដៅផែនដី ឥឡូវនេះគឺកំពុងត្រូវបានគេយកទៅពិចារណា។

## ■ ជំរើសផ្សេងៗទៀតសំរាប់ទឹក

ទន្លេឬស្ទឹង និងដីសើមជាច្រើនកន្លែងនៅជុំវិញពិភពលោកត្រូវបានគេធ្វើទំនប់កាត់និងបង្វែរដើម្បីផ្គត់ផ្គង់ទឹក។ ប៉ុន្តែភាគច្រើននៃទឹកទាំងនេះត្រូវខ្ជះខ្ជាយឥតប្រយោជន៍ដោយសារការស្រោចស្រពដែលគ្មានប្រសិទ្ធិផលនិងប្រព័ន្ធចែកចាយទឹកដែលលេចហូរទឹកចេញ។ ប្រជាជនដែលរស់នៅក្នុងទីក្រុងធំៗ ជាញឹកញាប់នាំគ្នាខ្ជះខ្ជាយទឹក។ ប្រសិនបើគេគ្រប់គ្រងទឹកបានល្អជាងធម្មតា វានឹងមានទឹកគ្រប់គ្រាន់ទៅតាមសេចក្តីត្រូវការរបស់មនុស្សគ្រប់គ្នា។ នៅខាងក្រោម ជាគំនិតមួយចំនួនដែលអាចជួយបាន។

### កាត់បន្ថយតម្រូវការ

កសិកម្មខ្នាតធំប្រើប្រាស់និងខ្ជះខ្ជាយទឹកសាបច្រើនណាស់។ ប្រព័ន្ធស្រោចស្រពដែលគេប្រើជាមួយកសិដ្ឋានធំៗជាច្រើន ជាញឹកញាប់ចំណាយទឹកទៅលើដីច្រើនជាងបរិមាណទឹកដែលរុក្ខជាតិត្រូវការ។ ទឹកដែលលើសតម្រូវការនោះបានបំផ្លាញដី។ គេអាចប្រើប្រភេទផ្សេងទៀតនៃប្រព័ន្ធស្រោចស្រពអាច ដើម្បីសន្សំទឹក។ ការស្រោចស្រពដែលស្រក់តក់ៗប្រើទឹកមានប្រសិទ្ធិភាពច្រើនជាង ពីព្រោះបញ្ចេញទឹកត្រង់តែឫសរបស់រុក្ខជាតិ។ ការស្រោចស្រពតក់ៗសន្សំទឹកនិងមានលក្ខណៈល្អជាងសំរាប់រុក្ខជាតិនិងដី។

កសិករខ្នាតធំជាច្រើ និងក្រុមហ៊ុនកសិកម្មធំៗជាច្រើន ពេលខ្លះដាំដំណាំជាច្រើននៅក្នុងតំបន់ក្តៅដែលត្រូវការទឹកច្រើន ដូចជាស្រូវនិងអំពៅ។ គេអាចសន្សំទឹកបានតាមរយៈជំរុញអោយកសិករខ្នាតធំនិងក្រុមហ៊ុនជាច្រើនអោយដាំដំណាំដែលមិនត្រូវការទឹកច្រើនពេក។

### ការត្រងយកទឹកភ្លៀង

ការត្រងយកទឹកភ្លៀងគឺជាវិធីដែលអស់លុយតិចនិងមានប្រសិទ្ធភាព ដើម្បីកែលំអលទ្ធភាពប្រើប្រាស់ទឹករបស់សហគមន៍ជាច្រើន។ ប្រជាជនអាចដាក់ធុងទឹកនៅជិតផ្ទះរបស់ពួកគេហើយត្រងយកទឹកភ្លៀងដែលហូរតាមដំបូលផ្ទះរបស់គេ។ ពាងពីដីធំៗអាចប្រើបានដែរសំរាប់ត្រងយកទឹកភ្លៀងសំរាប់ការប្រើប្រាស់ក្នុងផ្ទះ។

សំរាប់ការធ្វើកសិដ្ឋាន ប្រជាជន ជាញឹកញាប់កសាងទំនប់តូចៗ និងជញ្ជាំងតូចៗដើម្បីប្រមូលទឹកភ្លៀងទុកនៅពេលវាហូរចុះពីលើភ្នំ។ ទឹកជ្រាបចូលទៅក្នុងដី។ គេអាចធ្វើអណ្តូងដើម្បីចូលទៅដល់ទឹក។ វិធីផ្សេងទៀត គឺការកសាងទំនប់តូចៗនិងប្រឡាយនៅតាមស្ទឹងឬទន្លេ។ ទឹកក៏អាចប្រមូលបានដោយទំនប់ធ្វើពីឈើតូចៗ ថ្ម ឬ ដី បន្ទាប់មកត្រូវបានបង្វែរទិសចូលទៅក្នុងវាល។



## ប្រមូលទឹកភ្លៀងទុក ការផ្លាស់ប្តូរជីវិត



នៅក្នុងឆ្នាំ ១៩៨៦ ស្រុកអាលវ៉ា នៅក្នុងរដ្ឋរាចាស្ថាន ប្រទេសឥណ្ឌា គឺដូចជាវាលខ្សាច់។ ប្រជាជនមិនមានទឹកគ្រប់គ្រាន់សំរាប់ប្រើប្រាស់ក្នុងផ្ទះ និងចំការរបស់ពួកគេឡើយ។ នៅពេលនោះ ក្រុម តារុនបារ៉ាតសាង (TBS) ត្រូវបានបង្កើតឡើង ដើម្បីធ្វើអោយទឹកដែលមាននោះកើនឡើង។ ស្ថាបនិកនៃក្រុម **តារុន បារ៉ាតសាង** បានចាំថាប្រជាជននៅ រ៉ាចាស្ថាន ធ្លាប់ត្រងទឹកភ្លៀង។ នៅពេលដែលក្រុម TBS បានចាប់ផ្តើមការងាររបស់ពួកគេ រចនាសម្ព័ន្ធសំរាប់ប្រមូលទឹកភ្លៀងត្រូវបានគេបំផ្លាញនិងគ្មាននរណាម្នាក់ប្រើវាទៀតទេ។

ក្រុម TBS បានចងចាំអំពីគតិបណ្ឌិតដែលត្រូវបានគេបំភ្លេចទៅហើយនោះ ដែលនិយាយពីការប្រមូលយកទឹកភ្លៀង និងកសាងទំនប់តូចៗធ្វើពីដី ដែលបុព្វបុរសជំនាន់មុនរបស់ពួកគេបានកសាងកាត់តាមស្ទឹងឬទន្លេដើម្បីទប់យកនិងថែទាំទឹកភ្លៀងទុក។ នៅក្នុងរ៉ាចាស្ថាន ឥឡូវនេះមានទំនប់តូចៗនិងជញ្ជាំងធ្វើពីដីច្រើនជាង ១0000 កន្លែងដែលទប់យកបានទឹកភ្លៀងសំរាប់ភូមិជាង ១000 ភូមិ។ សូមអរគុណទំនប់និងជញ្ជាំងតូចៗជាច្រើន ឥឡូវនេះកំពស់ទឹកក្នុងដីគឺខ្ពស់ជាងមុន ហើយស្ទឹងដែលធ្លាប់តែរីងស្ងួតនោះ មានទឹកពេញមួយឆ្នាំៗ។ វាបានកែប្រែជីវិតរបស់ប្រជាជនប្រហែល ៧00 000 នាក់ អោយមានលទ្ធភាពប្រើប្រាស់ទឹកសំរាប់ផ្ទះសម្បែង ពសុសត្វ និង ដំណាំបានល្អជាងមុន។

ឡាចម៉ាបៃ ដែលជាស្ត្រីព្រឹទ្ធាចារ្យម្នាក់ដែលមកពីភូមិម៉ានដាវ៉ាល នៅក្នុង ចារាស្ថាន បាននិយាយថា ” មនុស្សច្រើនជំនាន់មុនយើង មិនមានសំណាងដូចអ្វីដែលយើងមាននេះទេ ” ។ ” ដោយសារតែទឹក យើងមានការសប្បាយចិត្ត សត្វពាហនៈរបស់យើងក៏សប្បាយដែរ ហើយសត្វព្រៃវាក៏សប្បាយ ” ។ទិន្នផលដំណាំរបស់យើង បានកើនឡើង ព្រៃឈើរបស់យើងឡើងពណ៌បៃតង យើងមានឧសដុត ចំណីសំរាប់សត្វពាហនៈរបស់យើង ហើយយើងថែមទាំងមានទឹកនៅក្នុងអណ្តូងរបស់យើងទៀតផង។

**សំណួរសំរាប់ការពិភាក្សា :**

- តើរឿងនេះទាក់ទងនឹងសហគមន៍របស់អ្នកដូចម្តេចខ្លះ?
- តើមានប្រព័ន្ធប្រមូលទឹកភ្លៀងលក្ខណៈប្រពៃណីនៅក្នុង

តំបន់របស់អ្នកដែរឬទេ?

- តើការយកមកប្រើឡើងវិញនូវប្រព័ន្ធទាំងនោះ អាចធ្វើអោយលទ្ធភាពមានទឹកប្រើប្រាស់របស់អ្នកកើនឡើងឬទេ?
- ប្រសិនបើអ្នកអាចជួយអោយប្រជាជនមួយចំនួនធំអាចផ្គត់ផ្គង់ទឹកប្រើប្រាស់ដោយខ្លួនគេបាន តើវាជួយអ្នកបញ្ឈប់ទំនប់បានដែរឬទេ?



## វិធីសផ្សេងៗទៀតសំរាប់ការគ្រប់គ្រងទឹកជំនន់

ពេលខ្លះ គេកសាងទំនប់ធំៗឡើងដើម្បីគ្រប់គ្រងទឹកជំនន់។ ទោះជាយ៉ាងណាក៏ដោយ នៅពេលណាមានទឹកជំនន់ធំមែនទែន ទំនប់អាចធ្វើអោយការខូចខាតមកពីទឹកជំនន់កាន់តែអាក្រក់ឡើង។ មានវិធីច្រើនណាស់ដើម្បីកាត់បន្ថយទឹកជំនន់ និងធ្វើអោយទឹកជំនន់ទាំងនោះមិនសូវបំផ្លាញផលប្រយោជន៏។ វាមានរួមទាំងការការពារ **ទីជម្រាល** និងការបង្កើតប្រព័ន្ធប្រកាសអាសន្នទឹកជំនន់។

### ការពារនិងស្តារទីជម្រាលឡើងវិញ

វិធីល្អបំផុតមួយនៅក្នុងចំណោមវិធីល្អបំផុតជាច្រើនទៀត ដើម្បីកាត់បន្ថយការខូចខាតដែលបណ្តាលមកពីទឹកជំនន់ គឺការពារនិងស្តារតំបន់ទីជម្រាលឡើងវិញ។ តំបន់ដីសើមដែលសំបូរជីវជាតិ តំបន់ទំនាបលិចទឹក និងព្រៃជាច្រើន បង្ការការជន់លិចទឹកដោយការទប់ទឹកអោយដក់នៅក្នុងនោះ។ ពួកវាដូចជាអេប៉ុងមួយដុំ។ ដើមឈើជាច្រើនជួយពន្យឺតល្បឿនរបស់ទឹកជំនន់ និងធ្វើអោយទឹកហូរចែកទិសដៅយឺតៗនៅលើតំបន់ទំនាបលិចទឹក។ ដីសើមស្រូបយកទឹកក្នុងពេលមានព្យុះ និងនៅពេលណាមួយដែលកំរិតទឹកឡើងខ្ពស់។ នៅពេលដែលកំរិតទឹកចុះទាប ដីសើមបញ្ចេញទឹកមកវិញយឺតៗ។



សព្វថ្ងៃនេះ មានតំបន់ដីសើម តំបន់ទំនាបលិចទឹក និង ព្រៃ ជាច្រើនកន្លែង ត្រូវបានបំផ្លាញ ដើម្បីយកកន្លែងកសាងផ្លូវថ្នល់ ផ្ទះ និង រោងចក្រ។ វាបានធ្វើអោយការខូចខាតដោយសារទឹកជំនន់កើនឡើង។ ដើម្បីអោយមានការគ្រប់គ្រងទឹកជំនន់ល្អប្រសើរមួយ គេត្រូវតែការពារធនធានធម្មជាតិទាំងនេះ។ ប្រសិនបើធនធានធម្មជាតិទាំងនេះត្រូវបានបំផ្លាញ គេត្រូវស្តារវាឡើងវិញ។

## បង្កើតប្រព័ន្ធប្រកាសអាសន្នទឹកជំនន់

រដ្ឋាភិបាលអាចបណ្តាក់ទុនលើប្រព័ន្ធប្រកាសអាសន្នទឹកជំនន់ ដើម្បីអោយប្រជាជនបានដឹងជាមុននៅពេលមានទឹកជំនន់មកដល់។ ការធ្វើបែបនេះអាចសង្គ្រោះជីវិតនិងកាត់បន្ថយការខូចខាតដោយសារទឹកជំនន់។ ប្រព័ន្ធប្រកាសអាសន្នដែលមានលក្ខណៈឆាប់រហ័ស ប្រាប់ប្រជាជនដែលរស់នៅតាមបណ្តោយមាត់ស្ទឹងទន្លេអោយបានដឹងនៅពេលណាទឹកជំនន់ហៀបនឹងកើតឡើង។ វាអាចនឹងពាក់ព័ន្ធដល់ការមានប្រដាប់បំពងសំលេងនៅក្នុងក្រុង និង មានផែនការគ្រាអាសន្ន ដែលចែងអំពីអ្វីដែលគេត្រូវធ្វើ ប្រសិនបើមានទឹកជំនន់កើតឡើង។ ប្រព័ន្ធដទៃទៀតធ្វើអោយប្រជាជនតាមដានមើល ថាតើទឹកក្នុងស្ទឹង ទន្លេ ឡើងខ្ពស់កំរិតណា។ នៅពេលដែលកំរិតទឹកឡើងខ្ពស់ហួសកំរិតជាក់លាក់មួយនោះ ប្រជាជនដឹងថា ទឹកជំនន់ទំនងជាកើតឡើង។



# សន្និដ្ឋាន

យើងសង្ឃឹមថា គោលការណ៍នាំសកម្មភាពនេះផ្តល់អោយអ្នកនូវឧបករណ៏និងព័តិមានជាច្រើន ដើម្បីជួយអ្នកនៅក្នុងការតស៊ូរបស់អ្នកប្រឆាំងនឹងទំនប់ដែលមានលក្ខណៈបំផ្លាញ។ យើងសង្ឃឹមផងដែរថា ជោគជ័យរបស់សហគមន៏ជាច្រើនញ៉ាំងអោយអ្នកហ៊ានការពារសិទ្ធិនិងជីវភាពរបស់អ្នក។ អ្នកមិនមែនប្រឹងប្រែងម្នាក់ឯងទេនៅក្នុងការតស៊ូរបស់អ្នក។

ប្រជាជនដែលរងការប៉ះពាល់ពីទំនប់ទឹក និង អង្គការក្រៅរដ្ឋាភិបាលបាននិយាយ នៅក្នុងឆ្នាំ ១៩៩៧ ថា:

" យើងខ្លាំង ចំរុះ និង រួបរួមគ្នា ហើយបុព្វហេតុរបស់យើងគឺត្រឹមត្រូវ។ យើងបាននិងកំពុងបញ្ឈប់ទំនប់ដែលមានលក្ខណៈបំផ្លាញជាច្រើន ហើយបានបង្ខំអោយអ្នកកសាងទំនប់អោយគោរពសិទ្ធិរបស់យើង។ យើងបញ្ឈប់ទំនប់ជាច្រើននៅក្នុងអតីតកាល ហើយយើងនឹងបញ្ឈប់បានច្រើនទៀតនៅក្នុងអនាគត។"

- *សេចក្តីប្រកាសមកពី " កិច្ចប្រជុំលើកទីមួយរបស់ប្រជាជនដែលរងការប៉ះពាល់ពីទំនប់ទឹក " នៅក្នុង គូរីទីបា ប្រទេសប្រេស៊ីល នៅថ្ងៃទ ១៤ ខែមិនា ឆ្នាំ ១៩៩៧។*

ពាក្យទាំងនេះត្រូវបានធ្វើអោយឃើញជាក់ស្តែងថា ក្លាយជាការពិត។ កាលណាយើងរួមគ្នា យើងអាចបញ្ឈប់ទំនប់បំផ្លាញបានជាច្រើន និងការពារសិទ្ធិរបស់ប្រជាជនយើង។ យើងរួបរួមគ្នា យើងអាចផ្តល់ថាមពលនិងទឹកតាមតម្រូវការរបស់ប្រជាជន ដោយមិនចាំបាច់ធ្វើអោយសហគមន៏មានការឈឺចាប់ និងបំផ្លាញបរិស្ថាន។

កាលណាយើងសាមគ្គីគ្នា យើងអាចកសាងអនាគតល្អជាងធម្មតាមួយ។



# ទំនាក់ទំនងប្រចាំតំបន់

International Rivers Network
1847 Berkeley Way
Berkeley CA 94703, USA
Phone: +1 510 848 1155
Email: info@irn.org
Web: www.irn.org

*ផ្តល់ការគាំទ្រដល់សហគមន៍មូលដ្ឋាននិង អង្គការក្រៅរដ្ឋាភិបាលដែលប្រឆាំងនឹងទំនប់ដែលមានលក្ខណៈបំផ្លាញ ។*

**អាហ្វ្រិក**

African Rivers Netework
C/- Mr. Frank Muramuzi
National Association of Professional Environmentalists (NAPE), Uganda
P.O. Box 29909
Phone: +256 77 492362
Email: nape@nape.or.ug
Web: www.nape.org.ug

*បណ្តាញរបស់សហគមន៍និងអង្គការក្រៅរដ្ឋាភិបាលតស៊ូមតិដើម្បីការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានទឹករបស់អាហ្វ្រិក ។*

Mr. Hpe Ogbeide
Society for Water and Public Health Protection (SWAPHEP), Nigeria 248 Uselu-Lagos Road, Ugbouto, Benin City, Nigeria.
Phone: + 234 803 742 4999
Email: swaphep@yahoo.com

SWAPHEP *ធ្វើការដើម្បីបង្កើនលទ្ធភាពរបស់ប្រជាជនមូលដ្ឋានក្នុងការបានទឹកស្អាតប្រើប្រាស់ និង លើកស្ទួយការគ្រប់គ្រងនិរន្តរភាពនូវធនធានទឹកសាប* ក្នុងប្រទេសនីសេរីយ៉ា ។

Ms. Liane Greeff
Environmental Monitoring Group, South Africa
PO Box 13378
7705 Mowbray, South Africa
Phone: + 27 21 448 2881
Email: rivers@kingsley.co.za
Web: www.emg.org.za

*ផ្តល់ការគាំទ្រដល់អង្គការនិងសហគមន៍ដែលធ្វើដើម្បីបញ្ឈប់ទំនប់និងការពារស្ទឹង ទន្លេនៅអាហ្វ្រិក ។*

**អឺរ៉ុប**

European Rivers Network
8 rue Crozatier,
43000 Le Puy, France
Phone: + 33 471 02 08 14
Email: info@rivernet.org
Web: www.ern.org

*បណ្តាញក្រុមជនជាតិអឺរ៉ុប អង្គការនិងប្រជាជនដែលធ្វើការដើម្បីការពារ ស្ទឹង ទន្លេ អឺរ៉ុប ។*

**អាមេរិកឡាទីន**

MAB-Movimento dos Atingidos por Barragens
HIGS Quadra 705, Asa Sul, Bloco K, Casa 11
Brasilia/DF, Brasil CEP: 70350-711
Phone: + 55 61 3242 8535
Email: mab@mabnacional.org.br
Web: www.mabnacional.org.br

*ចលនាជាតិប្រែជាជនដែលរងការប៉ះពាល់ពីទំនប់*

*របស់ប្រទេសប្រេស៊ីល ។*

Mr. Gustavo Castro Soto
Edupaz
Periferico Pte.17-8B, Cda. Cuatro Caminos
Col. San Martin; 29240
San Cristobal de Las Casas
Chiapas, Mexico
Phone: + 52 967 631 5474
E-mail: guscastro@lanerta.apc.org

*ជួយសម្របសម្រួលចលនា Mesoamerican ប្រឆាំងនឹងទំនប់ ។*

## អាស៊ីខាងត្បូង

Mr. Himanshu Thakkar
South Asian Network on Dams, Rivers and People (SANDRP)
86-D, AD block, Shalimar Bagh,
Delhi 110 088, India
Phone: + 91 11 2748 4654
Email: ht.sandrp@gmail.com
Web: www.sandrp.in

*ចែករំលែកព័ត៌មានអំពីការកសាងទំនប់នៅក្នុងប្រទេសឥណ្ឌានិងផ្តល់ទំនាក់ទំនងសំរាប់អ្នកប្រឆាំងនឹងទំនប់នៅក្នុងប្រទេសឥណ្ឌា ។*

Mr. Gopal Siwakoti 'Chintan'
Water and Energy Users Fedration-Nepal
G.P.O Box 2125
Kathmandu, Nepal
Phone: + 977 1 442 9741
Email: gopalchintan@gmail.com
Web: www.wafed-nepal.org

*បណ្តាញជាតិស្តីពីប្រជាជនដែលរងការប៉ះពាល់ពីគំរោងទឹកនិងថាមពលនិងក្រុមពាក់ព័ន្ធក្នុងមូលដ្ឋាននៅក្នុងប្រទេសនេប៉ាល ។ ជួយផងដែរ ក្នុងការសម្របសម្រួលបណ្តាញក្រុមដែលធ្វើការបញ្ហាទំនប់ និង ស្ទឹង ទន្លេនៅអាស៊ីខាងត្បូង ។*

Mr. Amjad Nzeer
Sungi Development Foundation
H.7-A, Street 10, F-8,3
Islamabad, Pakistan
Phone: +92 51 228 2481
Email: amjad.nazeer@sungi.org
Web: www.sungi.org

*ជួយសហគមន៏ការពារសិទ្ធិរបស់ពួកគេ និងទទួលផលចំណេញពីគំរោងអភិវឌ្ឍន៏នៅក្នុងប្រទេសប៉ាគីស្ថាន ។*

## អាស៊ីខាងកើត និងអាស៊ីខាងត្បូង

Rivers Watch East and Southeast Asia
c/- Ms. Joan Carling , RWESA Coordinator
Cordillera Peoples'Alliance
P.O. Box 975
2600 Baguio City, Philippines
Phone: + 63 74 442 2115
Email: joan@cpaphils.org
Web: www.rwesa.rog

*បណ្តាញអង្គការក្រៅរដ្ឋាភិបាលនិងប្រជាជនដែលរងការប៉ះពាល់ពីទំនប់ទឹកនៅក្នុងអាស៊ីខាងកើត និងខាងត្បូង ដែលធ្វើការដើម្បីបញ្ឈប់គំរោងអភិវឌ្ឍន៏ស្ទឹង ទន្លេ ដែលមានលក្ខណៈបំផ្លាញ ។*

Ms. Pianporn Deetes
Living Rivers Siam
78 Moo 10, Suthep Road, Tambol Suthep
Muang Chiang Mai 50200, Thailand
Phone: + 66 53 278 334
Email: pai@chmai2.loxinfo.co.th
Web: www.searin.org

*គាំទ្រសិទ្ធិរបស់សហគមន៍មូលដ្ឋានដើម្បីធនធាន*

*របស់ពួកគេនិងប្រឆាំនឹងការគំរាមកំហែងចំពោះស្ទឹង*

*ទន្លេនិងប្រព័ន្ធអេកូឡូស៊ី នៅក្នុងទ្វីបអាស៊ីអគ្នេយ៍ ។*

Friends of the Earth Japan
3-17-24-2F Majiro Toshima-ku
Tokyo 171-0031, Japan
Phone: +81 3 3951 1081
Email: finalce@foejapan.org
Web: www.foejapan.org

*ត្រួតពិនិត្យគោលនយោបាយ និង គំរោង ធនាគារ*

*ជប៉ុនសំរាប់សហប្រតិបត្តិការអន្តរជាតិ (JBIC) ។*

# អាស័យដ្ឋានទំនាក់ទំនងក្នុងប្រទេសកម្ពុជា

### វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្ដីពីកម្ពុជា

The NGO Forum on Cambodia

Tel:  (855-23) 214 429
Fax: (855-23) 994 063
#9 – 11, Street 476, Toul Tompoung 1,
P.O.Box 2295 Phnom Penh 3, CAMBODIA.
E-mail: ngoforum@ngoforum.org.kh
Website: www.ngoforum.org.kh

*NGO Forum បង្កើតឡើងដើម្បីចែករំលែកព័ត៌មានគ្នា ពិភាក្សាដេញដោល និងតស៊ូមតិលើបញ្ហាអាទិភាពនានា ដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ NGO Forum មានតួនាទីយ៉ាងសំខាន់នៅក្នុងការលើកឡើងនូវផលប៉ះពាល់នានា ដែលបណ្ដាលមកពីដំណើរការអភិវឌ្ឍន៍ និងការផ្លាស់ប្ដូរសេដ្ឋកិច្ច សង្គម និងនយោបាយដែលមានទៅលើប្រជាជនកម្ពុជា។*

### សមាគមថែរក្សាបរិស្ថាន និង វប្បធម៌

Culture and Environment Preservation Association (CEPA)

#59, Street 156, Sankat Phsar Depo 1, Khan Toul Kork,
Phnom Penh, Cambodia.
P.O.Box: 1486, CCC Box: 357
Tel:  (855-23) 881 613
Fax: (855-23) 369 179
E-mail: cepa@cepa-cambodia.org
Website: www.cepa-cambodia.org

*CEPA ជាសមាគមដែលបង្កើតឡើងមានគោលដៅដើម្បីធានាឱ្យបាននូវការថែទាំនិងការពារបរិស្ថាន និងធនធានធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសមធម៌ ឆ្ពោះទៅរកនិរន្តរភាពនៃការប្រើប្រាស់និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនិងកូនខ្មែរជំនាន់ក្រោយ។*

### បណ្ដាញការពារទន្លេសេសាន ស្រែពក សេកុង

Sesan, Srepok, Sekong Rivers Protection Network (SPN)

Banlung Town, Ratanakiri Province, Cambodia.
Tel: (855-75) 974 112
E-mail: sesan@camintel.com

*SPN គឺជាអង្គការសង្គមស៊ីវិលមូលដ្ឋានមួយមានស្នាក់ការកណ្ដាលនៅខេត្តរតនៈគិរី ដែលធ្វើការងារគាំទ្រដល់សហគមន៍ជនជាតិដើមភាគតិចដែលរស់នៅតាមដងទន្លេទាំង៣ សេសាន ស្រែពក និងសេកុង ដែលទទួលរងផលប៉ះពាល់ដោយសារការសាងសង់ទំនប់វារីអគ្គិសនីនៅក្នុងប្រទេសវៀតណាម និងឡាវ។*

International Rivers Network

Linking Human Rights and Environmental Protection